ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



ភាគទី ១

ផ្សាយ[illegible] "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

ទី ១

## កណ្ឌទសពរ

ប្រដាប់ដោយគាថា ១៩

បោះពុម្ពលើកទី ១
ចំនួន ១.០០០ ច្បាប់

**ភ្នំពេញ**

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥០៩

Websites: WatKhemaraRatanaram.org or WatKhmers.org

# ឧទ្ទិស

យើងខ្ញុំសូមឧទ្ទិសកុសលផលបុណ្យ ដែលកើតឡើង ពីការបោះពុម្ពផ្សាយឡើងវិញ នៃរឿងមហាវេស្សន្តរជាតកនេះ ជូនចំពោះវិញ្ញាណក្ខន្ធរបស់លោក ញ៉ុក ថែម ដែលជាអ្នករៀបរៀងចងក្រងរឿងមហាវេស្សន្តរជាតកនេះ និងអ្នកករីនិពន្ធខ្មែរទាំងឡាយដែលបានលាចាកលោកយើងនេះទៅមុនសម័យ ប៉ុល ពតក្ដី នៅក្នុងរបស់ប្រល័យ ប៉ុល ពត ក្ដី សូមវិញ្ញាណក្ខន្ធ នៃលោកទាំងអស់នោះបានទៅកើតនៅក្នុងសុគតិភពកុំបីខាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# អារម្ភកថា

## ចំពោះការបោះពុម្ពឡើងវិញ លើកទី ២

មហាវេស្សន្តរជាតក គឺជាស្នាដៃអក្សរសិល្ប៍បែបពុទ្ធនិយម មានលក្ខណៈប្រជាប្រិយ ល្បីល្បាញជាងគេក្នុងចំណោមរឿងជាតកនានា ។ រឿងមហាវេស្សន្តរជាតករៀបរាប់អំពីការកសាងបារមីពិសេស គឺទានបារមីរបស់ព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គយោនយកកំណើតជាព្រះពោធិសត្វ មានព្រះនាមថាព្រះវេស្សន្តរ ។

មហាជនប្រជាជនអ្នកកាន់ព្រះពុទ្ធសាសនា និយមស្តាប់ រឿងមហាវេស្សន្តរ តាមរយៈព្រះសង្ឃទេសនា នៅក្នុងឱកាសបុណ្យ ផ្សេងៗ តាមប្រពៃណីពុទ្ធសាសនា ដូចជាបុណ្យចេញវស្សា-បុណ្យ ភ្ជុំបិណ្ឌជាដើម ។ អត្ថបទរឿងមហាវេស្សន្តរជាតកប្រកបដោយ សិល្បវិធីនិពន្ធប្លែកពីរឿងដទៃ ដែលគេហៅថា "កម្រងកែវ" និង សម្បុរទៅដោយពាក្យពេចន៍ពីរោះជូនរណ្តំ បង្ហាញឲ្យឃើញនូវ លក្ខណៈពិសេស មួយទៀតខាងអត្ថបទរូបរបស់អក្សរសិល្ប៍ បែបពុទ្ធនិយម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ប៉ុន្តែគួរឲ្យសោកស្តាយក្រៃពេក ដោយរបបប្រល័យពូជសាសន៍ប៉ុល ពត អៀង សារី បានកំទេចពុទ្ធសាសនា និង ដុតបំផ្លាញគម្ពីរដីកា ស្នាដៃវប្បធម៌ អក្សរសាស្រ្តជាតិ ស្ទើរគ្មានសល់ ។ រឿងមហាវេស្សន្តរជាតក ក៏ទទួលរងនូវការបំផ្លិចបំផ្លាញ នេះដែរ ។

ក្រោយថ្ងៃជ័យជំនះ ៧ មករា ១៩៧៩ ប្រជាជនកម្ពុជាទូទាំងប្រទេស មិនគ្រាន់តែត្រូវបានសង្គ្រោះ ឲ្យរស់រានមានជីវិត ឡើងវិញប៉ុណ្ណោះទេ ថែមទាំងមានសិទ្ធិសេរីភាពគ្រប់បែបយ៉ាងនៅ ក្នុងជីវភាពរស់នៅក៏ដូចជាក្នុងជំនឿនិងសាសនាទៀតផង ។ ដោយបានទទួលការជួយឧបត្ថម្ភពីបក្សនិងរដ្ឋ គួបផ្សំនឹងស្មារតី សាមគ្គីរបស់ប្រជាជនពុទ្ធសាសនាក៏មានជីវិតឡើងវិញ ទន្ទឹមនឹង ការរស់រានឡើងវិញនៃវប្បធម៌អក្សរសាស្រ្តដែរ ។ ស្របគ្នានឹង កំណើតថ្មីរបស់ពុទ្ធសាសនានេះយើងខ្ញុំបានទទួលសំណូមពរពី មិត្តអ្នកអាននិងពុទ្ធសាសនិកជនជាច្រើន សុំឲ្យយើងខ្ញុំបោះពុម្ពរឿង ជាតកយើងវិញ ។ ឆ្លើយតបនឹងសំណូមពរខាងលើនិងជាជំហាន

ដំបូង យើងខ្ញុំបានទទួលការអនុញ្ញាត ឲ្យបោះពុម្ពផ្សាយឡើងវិញ នូវរឿងមហាវេស្សន្តរជាតក ដោយសាររឿងនេះមានសារសំខាន់ ជាងគេនៅក្នុងពិធីបុណ្យតាមប្រពៃណីពុទ្ធសាសនាផ្សេងៗ ។

ម៉្យាងទៀតការបោះពុម្ពឡើងវិញនេះក៏ដើម្បីៈ

រួមចំណែកដល់ការថែរក្សាទុក នូវកេរ្តិ៍ដំណែល សម្បត្តិ វប្បធម៌អក្សរសាស្ត្រជាតិ ដែលបុរាណាចារ្យរបស់យើងលោកបានបន្សល់ទុកតរៀងមក ។

បានជាឯកសារ អក្សរសាស្ត្រសំរាប់សិស្ស និស្សិត និងកូនចៅប្រជាជនកម្ពុជាជំនាន់ក្រោយ រៀនសូត្រអំពីសិល្បវិធី តែងនិពន្ធ ពាក្យពេចន៍ ឃ្លា ឃ្លោង របស់អ្នកនិពន្ធមុនៗ ។

ដើម្បីរក្សាតម្លៃស្នាដៃឲ្យនៅដូចដើម ក្នុងការបោះពុម្ពឡើងវិញ ពេលនេះយើងខ្ញុំចម្លងតាមច្បាប់ដើម ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី ១ ភ្នំពេញ ព.ស. ២៥០៩ ទាំងស្រុង ប៉ុន្តែយើងខ្ញុំយល់ថា ទោះបីយ៉ាងណាក៏យើងខ្ញុំពុំអាចចៀសផុតពីកង្វះខាតដោយប្រការផ្សេងៗ និងដោយអចេតនាឡើយ។

Websites: WatKhemaraRatanaram.org or WatKhmers.org

យើងខ្ញុំមានជំនឿជឿជាក់ថា អស់លោកអ្នកអានជាទីគោរព ប្រាកដជាយល់អធ្យាស្រ័យចំពោះកង្វះខាតទាំងនោះ និងសង្ឃឹមថានឹងបានទទួលមតិរិះគន់ស្ថាបនា ដើម្បីឲ្យការបោះពុម្ពលើក ក្រោយៗ កាន់តែល្អប្រសើរឡើង ។

ពាក្យបាលីខ្លះ ដែលមានភ្លាំងភ្លាត់ឃ្លាតចាកច្បាប់ដើម ក្នុងការបោះពុម្ពលើកមុនៗ យើងបានកែតម្រូវឡើងវិញក្នុងលើកនេះ ។ ចំណែកខាងសៀវភៅមួយក្បាល ដែលបោះពុម្ពរួមគ្នាទាំង ១៣ កណ្ឌពីមុននោះ ពុទ្ធសាសនបណ្ឌិត្យក៏នៅតែបោះពុម្ពឲ្យមានមួយផ្នែក តាមប្រក្រតីដដែល ។

ភ្នំពេញ, ថ្ងៃទី ១៥ មិថុនា ១៩៨៩

ពុទ្ធសាសនបណ្ឌិត្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

# កថាមុខ

## មហាវេស្សន្តរជាតក

ទំនៀមរបស់ស្រុកខ្មែរ តែកាលណាចេញវស្សាហើយ គេតែងចាត់ឲ្យមានបុណ្យទេសនាមហាជាតក៍ រឿងព្រះវេស្សន្តរជាតក ជាអឹកអធិក ស្ទើរតែគ្រប់វត្ត ជាទំនៀមដែលអ្នកស្រុកធ្លាប់ធ្វើរាល់ៗ ឆ្នាំ តាំងអំពីដើមរៀងៗ មក ទើបតែជាង ២០ ឆ្នាំមកនេះ ទំនៀមទេសន៍មហាជាតក៍នៅវត្តទាំងឡាយ ហាក់ដូចជារយោលសាបរលាប ឬលែងធ្វើសោះទៅក៏មាន ។

ក្នុងសម័យឥឡូវនេះ ទុកជាមានវត្តខ្លះ នៅនិយមធ្វើបុណ្យទេសន៍មហាជាតក ក៏មិនជាការរុងរឿងប៉ុន្មានទេ គ្រាន់តែនាំគ្នាធ្វើសោះតែខានប៉ុណ្ណោះ ម្ល៉ោះហើយ ទំនៀមទេសន៍រឿងមហាជាតកនេះក៏ចេះតែរៀវរោយចុះទៅជាលំដាប់ វត្តខ្លះក៏ខានធ្វើសោះ វត្តខ្លះក៏ធ្វើគ្រាន់តែជាគម្រប់ការ ។ ក្មេងវត្តជាន់ដើមស្គាល់ជាក់ច្បាស់ពិធីធ្វើបុណ្យទេសន៍មហាជាតក៍នេះ ព្រមទាំងចេះដឹងសេចក្តីផ្ទៃរឿងមហាវេស្សន្តរជាតកដោយសព្វគ្រប់ផង ។ ឯក្មេងវត្តក្នុងសម័យឥឡូវកម្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

មានការ ចេះដឹងរឿងព្រះវេស្សន្តរជាតកនេះណាស់ ក្មេងខ្លះមិនទាំងដែលឮគេនិយាយចេញឈ្មោះមហាជាតក៏នេះក៏សឹងមាន ។ មនុស្សសម័យជាន់ដើម កុំចាំបាច់និយាយដល់ក្មេងវត្ត សូម្បីក្មេងប្រុសស្រីនៅក្នុងស្រុកក្នុងភូមិក៏ធ្លាប់តែបានឃើញ បានដឹងឮពិធីបុណ្យទេសន៍មហាជាតក៏ ឬរឿងព្រះវេស្សន្តរជាតកនេះជាដំបូង ព្រោះជាបុណ្យចេញមុខចេញមាត់របស់ប្រជាជនជាងបុណ្យដទៃៗ ជាច្រើនយ៉ាងក្នុងសម័យនោះ ។

រីឯសេចក្ដីក្នុងផ្ទៃរឿងនៃមហាវេស្សន្តរជាតកនេះ តាមធម្មតាច្រើនតែមានលំនាំសេចក្ដីពីរោះចាប់ចិត្តអ្នកស្ដាប់ ទាំងព្រះសង្ឃទាំងគ្រហស្ថទូទៅ ដោយហេតុអស់លោកអ្នកប្រាជ្ញជាន់នោះ លោកខំប្រែរៀបរៀងពាក្យពេចន៍ឲ្យមានសម្ផស្សពាក្យទន់ភ្លន់ ព្រមទាំងសំនួនវោហារណែងណងទាក់ទងគ្នាជាពាក្យកម្រងកែវ ចងក្រងសេចក្ដីឲ្យពីរោះស្ដាប់ចាប់ត្រចៀក មិនឲ្យអ្នកស្ដាប់មានចិត្តធុញទ្រាន់ ហេតុនេះហើយ បានជាមានពួកឧបាសកឧបាសិកា ដែលមានសទ្ធាជ្រះថ្លាច្រើនគេអាចនឹងអង្គុយស្ដាប់ទេសន៍មហាជាតក៏នេះតាំងពីព្រលឹមរហូតដល់ព្រលប់ ឈប់សម្រាកតែពេលបរិភោគអាហារថ្ងៃត្រង់ប៉ុណ្ណោះ ហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

តាមធម្មតានោះ គេតែងចាត់ឲ្យមានបុណ្យទេសន៍មហាជាតក៏នេះ តែក្នុងមួយថ្ងៃឲ្យចប់សព្វគ្រប់ទាំង ១៣ កណ្ឌ ។

តាមទំនៀមរៀងៗ មកនោះ តែជិតដល់រដូវទេសន៍មហាជតក៏មុនថ្ងៃទេសន៍ប្រមាណ ៧ ថ្ងៃ, កន្លះខែ ឬ មួយខែ អាចារ្យក៏ចាត់ចែងសរសេរស្លាកប្រគេនព្រះសង្ឃឲ្យចាប់ លោកណាចាប់ស្លាកត្រូវទៅលើកណ្ឌណា ក៏យកកណ្ឌនោះមកហាត់ទេសន៍ឲ្យទាល់តែស្ទាត់រត់មាត់ល្អទាំងបាលីទាំងសម្រាយ ដល់វេលាឡើងទេសនា ក៏អាចទេសន៍បានហូរហែ មិនរអាក់រអួល ជាការនាំឲ្យបានស្រួលស្តាប់ផងអាចបំព្រួញពេលឲ្យបានខ្លីថែមទៀតផង គឺថាអាចទេសន៍គម្ពីរវេស្សន្តរជាតកនេះចប់ទាំង ១៣ កណ្ឌមុនថ្ងៃលិច ឬតាំងពីថ្ងៃរសៀលក៏មាន ។

ច្បាប់សាស្ត្រាមហាជាតក៏ទាំងឡាយ ដែលយើងបានពិនិត្យមើលជាច្រើនគម្ពីរក្នុងពួកគម្ពីរមហាជាតក៏ ដែលមាននៅក្នុងបណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យដែលបានច្បាប់មកអំពីខែត្រនានានោះឃើញថាមានលំនាំសេចក្តីខុសគ្នាខ្លះមួយអន្លើៗ ជួនកាលមានសេចក្តីវែងខ្លីលើសខ្វះគ្នាក៏មាន ក្នុងគម្ពីរមហាជាតក៏តែមួយមានកណ្ឌខ្លះ ខ្សែខ្លះ

Websites: WatKhemaraRatanaram.org or WatKhmers.org

មានពាក្យពេចន៍ ណែងណងចាប់ចុងចួនគ្នាជាល្បើកក៏មាន មានកណ្ឌខ្លះ គ្រាន់តែចងក្រងជាពាក្យកម្រងកែវក៏មាន កណ្ឌខ្លះមានបាលីគាថាពេញលេញក៏មាន កណ្ឌខ្លះសង្ខេបក៏មាន ច្បាប់មហាជាតក៍ខ្លះលើកយកបាលីគាថាមកដាក់តាំងជាច្រើនៗ ទើបប្រែជាសម្រាយហូរហែទៅក៏មាន ច្បាប់មហាជាតក៍ខ្លះ លើកយកបទគាថាមកតាំងជាគោលបន្តិចបន្តួច ហើយប្រែសេចក្តីហូរហែទៅតែម្តងក៏មាន ច្បាប់មហាជាតក៍ខ្លះ មានសេចក្តីបរិយាយត្រង់កន្លែងខ្លះ លើសកើនពីច្បាប់បាលីអដ្ឋកថាទៅក៏មាន មានកន្លែងខ្លះ លើកយកបាលី និង សេចក្តីប្រែគម្ពីរដទៃ មកដាក់បញ្ចូលថែមក៏មាន ។ល។ ប្រហែលជាគម្ពីរទេសន៍មហាជាតក៍នេះ កាលចាប់ផ្តើមធ្វើជាដំបូងនោះ ក្នុងមួយចប់មានលោកអ្នកតែងរៀបរៀងច្រើនរូប ឬ តែមួយរូប ៗ ទេ ប៉ុន្តែនៅវត្តដោយខ្លួន នៅខែត្រដោយខ្លួន ឬ មួយអស់លោកអ្នកផ្ទៀងផ្ទាត់ជាន់ក្រោយគិតកែសម្រួលតាមអត្តនោម័តិ ឬក៏កែតាមកាលសម័យជាន់នោះ ឬពុំនោះសោតអ្នកចារចម្លងជាន់ក្រោយបានកែថែមថយដោយខ្លួនឯង បានជាច្បាប់មហាជាតក៍ទាំងឡាយ មានសំនួនវោហារប្លែកផ្សេងពីគ្នាខ្លះ ដោយអន្លើៗ ដូចមានសេចក្តីសាស័ព្ទជាលំដាប់តទៅ ។

ដោយហេតុច្បាប់មហាជាតក៍ ជាទីនិយមរាប់អានសម្រាប់ប្រើទេសនាក្នុងវត្តទូទៅ ក្នុងប្រទេសខ្មែរយើងនេះ បានជាអស់លោកអាចារ្យជាន់នោះ គិតកែសម្រួលតម្រូវចិត្តមនុស្សក្នុងវត្តនីមួយ ៗ ដែលនិយមចូលចិត្តបែបណា ឬមួយកែសម្រួលតាមកាលវេលា គង់មានពួក ឧបាសក ឧបាសិកា ជើងវត្តខ្លះត្អូញត្អែរថា ច្បាប់មហាជាតក៍សម្រាប់វត្តយើងនេះពិស្តារពេក ទេសនាតាំងពីព្រលឹម រហូតដល់ព្រលប់នៅតែមិនទាន់ចប់ ក៏ត្រូវការមហាជាតក៍សង្ខេប ដោយហេតុនេះបានជាមានច្បាប់មហាជាតក៍ខ្លះកាត់បាលីគាថាចោលទៅជាច្រើនអន្លើ ច្បាប់ខ្លះកាត់ទាំងបាលីទាំងសម្រាយកាន់តែសង្ខេប ខ្លីទៅទៀតក៏មាន គ្រាន់តែប្រើទេសនាក្នុង ១ កំណាត់ថ្ងៃក៏ចប់អស់ទាំង ១៣ កណ្ឌ ។ ប៉ុន្តែគង់មានវត្តខ្លះ ពួកឧបាសក ឧបាសិកាជើងវត្ត ឬព្រះសង្ឃក្នុងវត្តនៅនិយមត្រូវការបែបពិស្តារក៏មាន បានជាមានច្បាប់មហាជាតក៍ខ្លះមានសេចក្តីពិស្តារ ចងក្រងជាពាក្យល្បើក ហើយមានបរិយាយវែងឆ្ងាយ ចេញក្រៅពីអដ្ឋកថាមហាវេស្សន្តរជាតកទៅទៀតក៏មាន ។

មួយវិញទៀត តួបាលីគាថាក្តី បាលីរាយមិនមែនជាគាថាក្តី

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីប្រែជាសម្រាយក្ដី ដែលល្អៀងឃ្លៀងឃ្លាត ឬភ្លាំងភ្លាត់ទៅជាច្រើននោះមកអំពីពួកអ្នកចារចម្លងក៏មាន ព្រោះតាមធម្មតា ពួកអ្នកចារមិនមែនសុទ្ធតែជាអ្នកចេះបាលីទេ មានខ្លះមិនសូវចេះដាក់អក្សរខ្មែរឲ្យបានត្រឹមត្រូវផងក៏មាន គ្រាន់តែជាអ្នកចេះចារអក្សរល្អប៉ុណ្ណោះ ហើយជាអ្នករកស៊ីចារសស្ត្រា ម្ល៉ោះហើយ ច្បាប់ចារចម្លងទាំងនោះ ប្រសិនបើមិនបានផ្ទៀងផ្ទាត់ថែមទៀត ក៏មិនបានជាត្រឹមត្រូវល្អទេ ថែមទាំងច្បាប់ដើមនោះ មានបើវិបត្តិសេចក្ដី ឬ វិបត្តិតួបាលីគាថាជាច្រើនផង ការចារចម្លងជាន់ក្រោយ ដោយពួកអ្នកស៊ីឈ្នួលចារទាំងនោះ ក៏កាន់តែនាំឲ្យមានការវិបត្តិច្រើនលើសពីច្បាប់ដើម ដែលមានវិបត្តិស្រាប់នោះទៅទៀត ។ កុំបាច់ពោលដល់ច្បាប់ដែលចារចម្លងជាន់ក្រោយ ៗ ត ៗ មកទៀតនោះឡើយ ។ មួយទៀតគួរជ្រាបថា ច្បាប់មហាជាតក៏ទាំងឡាយដែលចារដោយស្លឹករឹតនោះ មិនមែនសុទ្ធតែមានខុសវិបត្តិទៅទាំងអស់ទេ ត្បិតនៅមានច្បាប់ខ្លះ ក៏ត្រឹមត្រូវគួរសមដែរ ប៉ុន្តែបើពោលដោយយេភុយ្យន័យនោះ មិនមែនតែច្បាប់សាស្ត្រាមហាជាតក៏មួយទេ សូម្បីច្បាប់ចារស្លឹករឹតដទៃៗ ទៀត ក៏ច្រើនតែមានទំនងដូច្នោះដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯគម្ពីរមហាវេស្សន្តរជាតក ដែលយើងបានរួបរួមបោះពុម្ពឡើងនេះ ក៏មិនមែនជាច្បាប់ដែលយើងចាប់ប្រែ រៀបរៀងឡើងជាថ្មីទេ គឺយើងគ្រាន់តែយកច្បាប់សាស្ត្រា មហាជាតក៏ស្លឹករឹតទាំងនោះឯង មកពិនិត្យផ្ទៀងផ្ទាត់ ហើយចម្លងចេញបោះពុម្ពផ្សាយ ដើម្បីរក្សារបៀបរៀបរៀងសេចក្ដីជាន់ចាស់ទុកឲ្យគង់វង់តទៅផង ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងសម័យឥឡូវ ដែលមិនសូវបានស្គាល់ទេសន៍រឿងមហាវេស្សន្តរជាតកនេះផង ។ មួយវិញទៀតសូមឲ្យអស់លោកអ្នកមើល ច្បាប់មហាជាតក៏បោះពុម្ពនេះ ជ្រាបរបៀបរួបរួមផ្ទៀងផ្ទាត់បោះពុម្ពនេះដូចមានសេចក្ដីសាស័ព្ទតទៅនេះ ៖

១- តួបាលីគាថាក្ដី តួបាលីរាយមិនមែនជាគាថាក្ដី ក្នុងមហាវេស្សន្តរជាតកច្បាប់ស្លឹករឹតនោះ ឃើញមានវិបត្តិជាច្រើនអន្លើ ទើបយើងផ្ទៀងផ្ទាត់កែសម្រួលឲ្យបានត្រឹមត្រូវឡើង តាមរបៀបបាលីក្នុងគម្ពីរអដ្ឋកថាមហាវេស្សន្តរជាតក និងច្បាប់បាលីដើម ។

២- សេចក្ដីប្រែរៀបរៀងជាសម្រាយនោះ យើងបានរក្សាទុកតាមច្បាប់ដើមស្ទើរតែទាំងអស់ វៀរលែងតែច្បាប់ដើមដែលរំលងសេចក្ដីបាត់ទៅដោយអ្នកចារ ៗ ចម្លង ទើបយើងប្រែរៀបរៀងជាថ្មី

Websites: WatKhemaraRatanaram.org or WatKhmers.org

បំពេញសេចក្ដីត្រង់ដែលបាត់នោះ។ តួបាលីគាថាដែលរំលងបាត់ ទៅក៏ស្រង់យកមកដាក់បំពេញដែរ ។

៣- ច្បាប់មហាជាតក៏ទាំងឡាយ ដែលមានសេចក្ដីប្លែកផ្សេងពីគ្នាដោយសំនួនវោហារក្ដី ដោយសេចក្ដីលើសខ្វះពីគ្នាក្ដី ដោយ រូបសេចក្ដីខុសគ្នាទាំងបាលី ទាំងសម្រាយក្ដី យើងក៏បានបង់លេខ ធ្វើនយលក្ខណៈទុកដោយអន្លើៗ បង្ហាញឲ្យឃើញសេចក្ដីប្លែកផ្សេងគ្នានោះៗ ។ ត្រង់ដែលមានសេចក្ដីប្រែល្អៀងឃ្លៀងឃ្លាត ពីរូបបាលីទៅខ្លះ យើងក៏ធ្វើនយលក្ខណៈប្រែសេចក្ដីតាមរូបបាលី បង្ហាញឲ្យឃើញសេចក្ដីប្លែកផ្សេងគ្នាដែរ ។

៤- ត្រង់ដែលមានសេចក្ដីពណ៌នាអំពី ព្រៃព្រឹក្សាលតាវល្លិក្ដី អំពីបក្សាបក្សីក្ដី អំពីសត្វទ្វិបាទចតុប្បាទក្ដី អំពីមច្ឆាជាតិទាំងឡាយក្ដី គប្បីយល់ថា សេចក្ដីប្រែរៀបរៀងរបស់លោក អំពីបុរាណរៀងមកនោះ មិនបានប្រឹតប្រៀនឲ្យត្រឹមត្រូវតាមរូបបាលីប៉ុន្មានទេ គឺត្រូវការសេចក្ដី និងសម្ផស្សពាក្យចូនជាប្រមាណ ជាទំនងសេចក្ដីកម្រងកែវ ឬជាពាក្យល្បើក ដែលនាំឲ្យពីរោះស្ដាប់ចាប់ចិត្តជនទាំងពួង ។

៥- ច្បាប់មហាជាតក៏បោះពុម្ពនេះ យើងបានកែអក្សរខុស

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រូវ តម្រូវតាមរបៀបប្រើអក្សរ ក្នុងសម័យបច្ចុប្បន្ននេះ ព្រោះរបៀបអក្សរសាស្ត្រខ្មែរក្នុងសម័យសព្វថ្ងៃនេះ ក៏កាន់តែចម្រើនគួរសមហើយ មានវចនានុក្រមខ្មែរ សម្រាប់ផ្ទៀងផ្ទាត់ដាក់ពាក្យពេចន៍ឲ្យបានត្រឹមត្រូវហើយ ទើបគួរផ្លាស់របៀបដាក់អក្សរតាមបែបថ្មី តែសំនួនវោហារ និងសេចក្តីរៀបរៀងទុកនៅតាមរបៀបជាន់ចាស់ដដែល គឺអក្សរសម័យថ្មី ឯសេចក្តីសម័យចាស់ ។

៦- តាមច្បាប់មហាជាតក៍សម្រាយ ក្នុងមួយខ្សែៗ សុទ្ធតែមានចំណងជើង ប្រាប់ចំនួនគាថា ថាមានគាថាប៉ុណ្ណោះៗ ប៉ុន្តែមិនសូវមានខ្សែណាមានចំនួនគាថាគ្រប់គ្រាន់តាមចំណងជើងនោះឡើយ ។ ឯច្បាប់មហាជាតក៍បោះពុម្ពនេះយើងបានស្រង់យកតួបាលីគាថា មកដាក់បំពេញតាមច្បាប់បាលីដើមទាំងអស់ ដើម្បីបង្គ្រប់ចំនួនគាថាតាមចំណងជើងក្នុងកណ្ឌនីមួយៗ ។ (ដែលលោករាប់ជាមួយគាថាៗ នោះមិនសូវជាកំណត់ទៀងទាត់ទេ ព្រោះមានគាថាក្នុងកណ្ឌខ្លះ មាន ២ បាទ ៤ បាទ ៥ បាទ ៦ បាទ រាប់ជាមួយគាថាក៏មាន) ។ មួយវិញទៀត ការស្រង់យកបាលីគាថាមកដាក់បំពេញដូច្នេះ នាំឲ្យមើលឃើញតួបាលីច្រើនស្អេកស្កះ ដែលអាចនាំឲ្យមានសេចក្តីធុញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រាន់ ដល់អ្នកទេសន៍និងអ្នកស្តាប់ ឬអ្នកអានមើលច្បាប់មហាជាតក៍ បោះពុម្ពនេះខ្លះមិនខាន ប៉ុន្តែហេតុប៉ុណ្ណោះមិនជាការក្រទេ គឺ វេលាទេសន៍ឬអានមើល កាត់រំលងតួបាលីគាថា ទៅទេសន៍ឬអាន តែសម្រាយទទេក៏បានដែរ ជាការបង្រួញពេលវេលាឲ្យបានខ្លី តាមសេចក្តីត្រូវការរបស់វត្តខ្លះ ។

៧- សេចក្តីត្រង់ណាមិនមានរឿងសំដែងទុក ក្នុងគម្ពីរអដ្ឋកថា ឬ ក្នុងច្បាប់បាលីដើមទេ ប៉ុន្តែមានសេចក្តីរៀបរៀងល្អស្តាប់ទាំងសមហេតុសមផលផង (ដូចជាក្នុងកណ្ឌជូជក តាំងពីចាប់ផ្តើមសាស័ព្ទ អំពីដំណើរជូជកដើរសុំទាន ដរាបដល់បាននាងអមិត្តតាបនានាំទៅលំនៅអាត្មាឯកលិង្គរាស្ត្រ) យើងក៏បានរក្សាទុក តាមច្បាប់ចាស់ទាំងអស់ ហើយធ្វើនយលក្ខណៈ ប្រែសេចក្តីតាមរបៀបបាលីអដ្ឋកថាឲ្យបានដឹងផង ។ វៀរលែងតែសេចក្តីត្រង់ណាចេញក្រៅបាលីហើយមិនសមហេតុផល ហើយជារឿងកំប្លែងលេងសើចទេ ( ដូចជាក្នុងកណ្ឌមហារាជបព្វៈ ត្រង់រឿងជូជកបរិភោគអាហារទាល់តែចាក់ប្រាសធ្លាយពោះស្លាប់) ក៏យើងមិនកាត់ចោលច្បាប់ចាស់ស្រឡះដែរ គឺធ្វើនយលក្ខណៈ រក្សាទុកនៅខាងក្រោយកណ្ឌនោះគ្រាន់តែមិនបាន

Websites: WatKhemaraRatanaram.org or WatKhmers.org

បញ្ចូលមកទុកក្នុងផ្ទៃរឿងប៉ុណ្ណោះ ។

៨- របៀបប្រើពាក្យពេចន៍ ឬស័ព្ទសែងក្នុងគម្ពីរមហាជាតក៍សម្រាយនេះ ពិតមែនតែជាគម្ពីរ ដែលបានប្រែមកអំពីអដ្ឋកថាមហាវេស្សន្តរជាតកបាលី ប៉ុន្តែមានជាប់សំដីសំស្រ្កឹតជាច្រើនក្នុង សេចក្តីប្រែជាសម្រាយ សូម្បីតែឈ្មោះមនុស្ស សត្វ ឬវត្ថុអ្វីៗ ក៏ប្រែ ទៅជាពាក្យសំស្រ្កឹតដែរ ដូចជាព្រះនាមព្រះវរមាតាព្រះបាទស្រី វេស្សន្តរតាមស័ព្ទបាលីថា "ផុស្សតិ" ក៏ប្រែទៅជាស័ព្ទសំស្រ្កឹតថា "សុបារសុប្បតី (សំស្រ្កឹតក្លាយ ? គួរជា "ស្បុត្បិតី ឬ ស្បុត្បិតី" ។ ព្រះនាមព្រះអគ្គមហេសី តាមស័ព្ទបាលីថា "មទ្ទី" កែជា "មទ្រី" ។ ព្រះនាមព្រះរាជធីតាថា "កណ្ហា" ក៏កែជា "ក្រឹស្ណា" ឈ្មោះអ្នកស្រុកថា "ចេតរដ្ឋ" ក៏កែជា "ចេតរាស្រ្ត" ដូច្នេះជាដើម ។ (នេះសឲ្យឃើញ និស្ស័យសន្ដានចិត្តខ្មែរជាន់ដើម ចូលចិត្តនិយមរាប់អានពាក្យសំស្រ្កឹត ជាងមគធភាសា ឬមួយជាប់ទម្លាប់មាត់ថាតាមសំស្រ្កឹតមកយូរ អង្វែងហើយ ទុកជាគ្រាក្រោយបែរមកនិយម រៀនសូត្របាលីភាសា ជាជំនួសសំស្រ្កឹតវិញហើយ ប៉ុន្តែទម្លាប់មាត់ថាតាមសំស្រ្កឹតនេះងាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រួលជាងទាំងពីរោះពិសាជាងបាលីដែលជាភាសាចំណូលថ្មីទើបនៅតែចង់ប្រើពាក្យសំស្រ្កឹតដូចជាន់មុនដដែល) ។

៩- គម្ពីរវេស្សន្តរជាតកដែលបោះពុម្ពនេះ ចែកចេញជាកណ្ឌមាន ១៣ កណ្ឌ គឺ កណ្ឌទសពរ ១ ហេមពាន្ត ១ ទានកណ្ឌ ១ វនប្បវេសន៍ ១ ជូជក ១ ចូឡពន ១ មហាពន ១ កុមារបព្វៈ ១ មទ្រីបព្វៈ ១ សក្កបព្វៈ ១ មហារាជបព្វៈ ១ ឆក្សត្រិយ៍ ១ នគរកណ្ឌ ១ ។

ក្នុងទីបំផុតនៃកថាមុខនេះ យើងមានសង្ឃឹមទុកជាមុនថា អស់លោកអ្នកស្វែងរកចំណេះដឹង ខាងផ្លូវអក្សរសាស្ត្រខ្មែរ គង់មានសេចក្ដីពេញចិត្តចំពោះ សំនួនវោហាររបៀបរៀបរៀងសេចក្ដីនៃច្បាប់មហាជាតក៏ជាន់ដើមនេះខ្លះមិនខាន ព្រោះវិធីតែងសេចក្ដី ឬ រៀបរៀងប្រែរឿងអ្វី កាលពីជាន់ដើមនោះ មិនមែនជាថយខ្សោយរសជាតិជាងសម័យឥឡូវប៉ុន្មានទេ ។ ប្រសិនបើយើងយកចិត្តទុកដាក់ពិនិត្យដោយហ្មត់ចត់ទៅ នឹងឃើញថា របៀបរៀបរៀងសេចក្ដីជាន់ដើមមានលំនាំសេចក្ដី និងសម្ផស្សពាក្យ ល្អជាងជាន់ឥឡូវទៅទៀត បើ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពោលចំពោះត្រង់សេចក្ដីពណ៌នាអំពីព្រៃព្រឹក្សា បក្សាបក្សីផង ក៏កាន់តែមានសម្ផស្សពាក្យពីរោះស្ដាប់ចាប់ចិត្ត ជាងជាន់ឥឡូវជាអនេកប្រការ សូម្បីសេចក្ដីតែងជាពាក្យកាព្យ ដែលលោកពោលពណ៌នាពីព្រៃព្រឹក្សាលតាវល្លិ ក៏មានសម្ផស្សពាក្យល្អស្ដាប់ចាប់ចិត្តនៃចិន្តកវីជំនាន់ថ្មីនេះណាស់ដែរ ហើយច្រើនតែជា របៀបតែង ឬ ប្រែដោយចំណេះចេះដឹងតាមបែបខ្មែរសុទ្ធផង ទើបគួរតែអ្នកសិក្សាអក្សរសាស្ត្រខ្មែរ សម័យឥឡូវ ពិនិត្យមើលរបៀបតែងសេចក្ដីជាន់ចាស់ខ្លះពុំគួររំលងចោលស្រឡះទៅទេ ។

អ្នករួបរួមផ្ទៀងផ្ទាត់
ហ្លួងនិពន្ធ ញ៉ុក ថែម
ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

ទី ១

## ទានកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ផុស្សតី វរវណ្ណាភេតិ ឥទំ សត្ថា កាបិលវត្ថុំ ឧបនិស្សាយ និគ្រោធារាមេ វិហរន្តោ បោក្ខរវស្សំ អារព្ភ កថេសិ ។

សត្ថា មោះ សត្ថវាហោ សត្ថជាយកោ រីព្រះអង្គដ៏ជាគ្រូប្រសើរក្រៃលែង តែងអាចនាំអស់ទេវតាមនុស្ស សត្វផងទាំងឡាយកៀរគរបរប្រមូល បញ្ចូលទៅកាន់អម្រឹតបុរី ស្រីមហានគរនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្តប្រេមប្រាស និរាសទុក្ខប្រសើរហោង ។

វិហរន្តោ មោះ ចតូសុ ឥរិយាបថេសុ រីតិជាមេន្តោ ក៏ព្រះអង្គ គង់សម្រេចសម្រាន្តក្សាន្តនូវព្រះឥរិយាបថ ស្រគត់ព្រះអង្គនោះមានបួន ពុំឲ្យច្នួននូវសន្និះតម្រិះចិត្តនៃទេវតាមនុស្ស សត្វផងទាំងឡាយឡើយ និគ្រោធារាមេ ក៏ព្រះអង្គគង់ព្វដ៏ឋានអារាមនាម

Websites: WatKhemaraRatanaram.org or WatKhmers.org

ហៅនិគ្រោធមហាវិហារ គឺថៅនិគ្រោធកុមារ ចាយវាយមាស ១២ កោដិតម្លឹង សាងថ្វាយព្រះអង្គ ឧបនិស្សាយ ក៏ព្រះអង្គអាស្រ័យយក ព្រះបិណ្ឌបាត សង្វាតសន្តោសប្រោសសត្វផងទាំងឡាយ កាបិលវត្ថុំ ឰដ៏ស្រុកកបិលពស្តុបុរី ស្រីមហានគរបវររាជដ្ឋាន អារព្ភ មោះ អារម្មណំ កត្វា ទើបព្រះអង្គមានព្រះបន្ទូលធ្វើឲ្យជាហេតុជាអារម្មណ៍ បន្តិច ហើយទើបព្រះអង្គឆ្ពោះ ចោក្ខរវស្សំ នឹងភ្លៀងស្ទូគិមួយឈ្មោះ បោក្ខរព័ស៌ កាថេសិ មោះ ឧម្មំ ទេសេសិ ទើប ព្រះអង្គសំដែងថ្លែងព្រះធម៌វិសេសទេសនា ឥទំ មហាវេស្សន្តរជាតកំ សហស្សគាថាបដិ-មណ្ឌិតំ បពិត្រអើយ នេះនឹងនិទានដំណើរដំណាលកាលព្រះអង្គ ត្រាច់រង្គាត់នៅនាក្នុងវដ្តសង្សារ ត្រអាលយោនយកកំណើត កើតជា ព្រះពោធិសត្វមួយព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរហៅថាព្រះមហា វេស្សន្តរ មហាវេស្សន្តរជាតកនេះ ដ៏ប្រដាប់ប្រដានូវព្រះគាថានោះ មួយពាន់ អត្ថជា មោះ ឧបលិក្ខិតេឯ គឺកំឡាំងព្រះប្រាជ្ញាសព្វញ្ញុ ពុទ្ធ ដ៏ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ព្រះអង្គអាចសំគាល់ដឹងបាន

Websites: WatKhemaraRatanaram.org or WatKhmers.org

អាទិតាថាបនេន ដោយនូវគន្លងទំនងដើមបទកំណត់អក្សរបវរ ព្រះគាថានេះដ៏ជាអាទិ៍ ផុស្សតី វរវណ្ណាភេតិ នេះឯងគឺដ៏ជាប្រធានដើមបទព្រះអង្គកត់កំណត់ត្រង់ណោះឯងហោង ។

យទា ហិ សត្ថា បវត្តិតប្បវរធម្មចក្កោ អនុក្កមេន រាជគហំ គន្ត្វា តត្ថ ហេមន្តំ វីតិនាមេត្វា ឧទាយិត្ថេរេន មគ្គទេស-កេន វីសតិសហស្សខីណាសវបរិវុតោ បឋមគមនេន យាវ កបិលវត្ថុំ អគមាសិ ។

បពិត្រអើយ នាកាលព្រះដ៏មានបុណ្យ ព្រះអង្គបានត្រាស់ប្រាជ្ញាសព្វេញ្ញុតាញាណជាបឋមនោះ ស្តេចលីលាទៅកាន់ព្រៃឥសិ-បតនមិគទាយពន ព្រះអង្គទេសនា ព្រះធម្មចក្កប្បវត្តនៈដ៏ប្រសើរដំណើរសេងគុណបញ្ចវគ្គិយភិក្ខុទាំង ៥ មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាប្រធាន បានលុះស្រោតាបត្តិផល មួយអន្លើនឹងមហាព្រហ្មទាំង ១៨ កោដិ សោតសឹងបានលុះស្រោតាបត្តិផល ដល់ប្រាជ្ញាអរហន្តទីទៃៗ ស្រេចហើយនៃ ទើបស្តេចលីលាពីនោះឆ្ពោះទៅកាន់នគររាជគ្រឹះបុរី ប្រយោជន៍ដើម្បីនឹងដោះពាក្យប្តេជ្ញាព្រះបាទមគធរាជ ដ៏

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាឧបាសកអំពីបុរាណកាល បើព្រះដ៏មានបុណ្យ ព្រះអង្គស្តេចទៅដល់នគររាជគ្រឹះនោះហើយ ព្រះអង្គសំដែងព្រះធម៌ វិសេសទេសនាដោះពាក្យប្តេជ្ញាជាសណ្តាប់ នៃព្រះបាទមគធរាជនោះហោង ។

បពិត្រអើយ កាលនោះរីមហាជនទាំងឡាយ សឹងកាន់នីទៅនូវទៀនធូបគន្ធមាលា ផ្កាភ្ញីចូលទៅបូជា ព្រះដ៏មានបុណ្យនោះច្រើនក្រៃពេក ។ កាលណាបើបានបូជាព្រះដ៏មានបុណ្យនោះស្រេចហើយ ក៏អង្គុយស្តាប់នូវស័ព្ទព្រះធម៌វិសេសទេសនា ដ៏ផ្អែមល្ហែមពីរោះដូច្នេះក្តី សឹងចូលចិត្តត្រេកអរសាទរ ហើយសរសើរថា ឱ ! ធម៌ទេសនាព្រះដ៏មានបុណ្យអើយ ! ពីរោះអ្វីមាល្បាយអេះ ! ម្ល៉ោះហើយអស់មហាជនផងទាំងឡាយ ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាបានឡើយ នឹងពិតទូលសូមផ្នួសបួសក្នុងសំណាក់ព្រះអង្គនោះប្រមាណមួយម៉ឺនជាបរិវារ ឰដ៏កាលនោះហោង ។

បពិត្រអើយ នាកាលព្រះដ៏មានបុណ្យ ស្តេចទេសនាជាសណ្តាប់ នៃព្រះបាទមគធរាជនោះស្រេចហើយ ស្តេចគង់សម្រេចនូវព្រះក្រិត្យជាព្រះពុទ្ធចំហុតអស់ខែហេមន្តរដូវក្តី ក៏មិនកំបាំងបាត់

ស្វាត់ ប៉ុន្តែក្នុងកម្លុងស្រុករាជគ្រឹះនោះឡើយ ក៏ឮជ្រួតជ្រាបដរាបទៅដល់ព្រះស្រោត្រទិព្វថ្លៃ នៃព្រះបាទស្រីសុទ្ធោទន មហារាជជាសម្តេចព្រះវររាជបិតា ព្រះអង្គទ្រង់ជ្រាបហើយ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថា ឱ! ឥឡូវនេះអ្នកសិទ្ធាថ៌កុមារកូនអញ អញគិតស្មានជាអ្នកទៅបួសបាត់ស្វាត់ទៅហ: ក៏ឥឡូវនេះលេចឮដំណឹងថា អ្នកបានត្រាស់ប្រាជ្ញាសព្វេញ្ញូតាញាណជាព្រះពុទ្ធហើយ អ្នកគង់នៅនារាជគ្រឹះបុរី ហើយអ្នកទេសនាជាសណ្តាប់ព្រះបាទមគធរាជ ឥឡូវអញរលឹកកូនអញណាស់ ថាបើដូច្នោះធ្វើម្តេចអញនឹងបានឃើញកូនអញហ: នេះមានតែអញនឹងប្រើទូតទៅនិមន្តអ្នកមកក៏បានអេះ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណា នូវប្រការអម្បាលណោះហើយ ទើបមានព្រះបន្ទូលត្រាស់ប្រើរាជអាមាត្យមួយដ៏ជាធំថា នៃរាជអាមាត្យ អញឮថាអ្នកសទ្ធាថ៌កូនអញមិញ អ្នកបានត្រាស់ប្រាជ្ញាសព្វេញ្ញូតាញាណហើយអ្នកមកគង់នៅនគររាជគ្រឹះហើយ ក៏ឥឡូវនេះ អញនឹងប្រើបាឯងនាំពលមួយពាន់ ទៅអារាធនានិមន្តអ្នកមកឥឡូវហោង ។ នៃអាមាត្យថាបើអ្នកទទួលនិមន្ត ក៏ចូរបានាំអ្នកមកឲ្យឆាប់ កុំបីយូរឡើយ ។ រាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

អាមាត្យទទួលព្រះបន្ទូលព្រះមហាក្សត្រហើយ ក្រាបថ្វាយបង្គំលានាំបរិពារមួយពាន់ ដើររៀងរាបដរាបទៅដល់នគររាជគ្រឹះនោះឯង ។ កាលបើបានដល់ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ប្រយោជន៍ដើម្បីនឹងសូមអារាធនានិមន្ត ដូចព្រះបណ្ដាំព្រះមហាក្សត្រាធិរាជនោះ កាលណាបានឮព្រះធម៌ទេសនាដ៏ពីរោះផ្អែមល្ហែមដូច្នោះក្ដី រាជអាមាត្យមួយអន្លើនិងពលមួយពាន់នោះ ក៏ភ្លេចភ្លាំងស្មារតី ពុំអាចដើម្បីនឹងពិតទូលអំពីព្រះបណ្ដាំព្រះមហាក្សត្រនោះឡើយ ក៏ខ្វែប្រែជាពិតទូលសូមផ្នួសបួសអស់ទាំងមួយពាន់នោះវិញហោង ។

បពិត្រអើយ រីរាជអាមាត្យទាំងមួយពាន់នោះសោត កាលបើបានបួសស្រេចហើយក្ដី នៅជាសុខសប្បាយ ពុំភ្លឹករលឹកអំពីព្រះបណ្ដាំព្រះមហាក្សត្រនោះឡើយ ។ រីព្រះបាទស្រីសុទ្ធោទនមហារាជទន្ទឹងយល់បាត់ស្ងាត់ហើយ ស្ដេចប្រើរាជអាមាត្យមួយវិញទៀតឲ្យនាំពលមួយពាន់នាក់ទៅទៀត លុះទៅដល់យល់ព្រះអង្គហើយ ក៏ពិតទូលសូមផ្នួសបួសអស់ទាំងមួយពាន់នោះឯងហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបាទស្រីសុទ្ធោទនមហារាជ ព្រះអង្គទ្រង់ប្រើបណ្តើរ រៀងៗ ទៅ លុះគ្រប់ ៩ ដង អស់រាជអាមាត្យទាំង ៩ ពាន់នោះ សឹងតែព្រះអង្គបំបួសអស់ ឥតសេសសល់សំណល់ដល់មួយឡើយ ។ រីឯព្រះបាទស្រីសុទ្ធោទនមហារាជមិញ ទ្រង់ទន្ទឹងយល់បាត់ស្ងាត់អម្បាលនោះហើយ ទើបព្រះអង្គប្រើរាជអាមាត្យមួយវិញទៀត ឈ្មោះឧទាយិអាមាត្យថា ម្នាលឧទាយិអាមាត្យអើយ អញចង់ប្រើបាឯងទៅនិមន្តអ្នកសិទ្ធាថិកូនអញបន្តិចហ: ត្បិតអញប្រើអស់រាជអាមាត្យអំពីមុននោះ ៩ ពាន់ បាត់ស្ងាត់អស់ទាំងអម្បាលណោះ មិនបានរួចមកដល់មួយនាក់ឡើយ ក៏ឥឡូវនេះអញយល់តែបាឯង មានគំនិតស្មារតីបានដឹងគំនិតអញ អញនឹងប្រើបាឯងនាំពល ១.០០០ ទៅកាន់រាជគ្រឹះនគរនោយនោះ ថាបើបាបានទៅដល់យល់អ្នកហើយ ក៏ចូរបាសូមអារាធនានិមន្តអ្នកមកឲ្យឆាប់ កុំបីយូរឡើយ ។ ឧទាយិអាមាត្យទទួលយកព្រះបន្ទូលមហាក្សត្រាធិរាជនោះស្រេចហើយ ក្រាបថ្វាយបង្គំលានាំបរិពារពលមួយពាន់ ដើររៀងរាបដរាបទៅដល់រាជគ្រឹះបុរីស្រីមហានគរបវររាជដ្ឋាននោះឯងហោង ។

Websites: WatKhemaraRatanaram.org  or  WatKhmers.org

កាលណាបានដល់ទៅយល់ព្រះដ៏មានបុណ្យហើយ ក៏ចូលទៅក្រាបថ្វាយបង្គំប្រណម្យ ប្រយោជន៍ដើម្បីនឹងសូមអារាធនានិមន្តដូចព្រះបណ្តាំព្រះមហាក្សត្រនោះមិញ លុះឮឯព្រះធម៌ទេសនាព្រះអង្គពីរោះដូច្នោះក្ដី ឧទាយិអាមាត្យ មួយអន្លើនិងពលទាំងមួយពាន់នោះក៏ភ្លេចភ្លាំងស្មារតី ពុំអាចដើម្បីនឹងពិតទូល អំពីបណ្ដាំព្រះមហាក្សត្រនោះបានឡើយ ហើយខ្ញែប្រែជាពិតទូលសូមផ្នួសបួសទាំងអស់មួយពាន់នោះវិញហោង ។ រីព្រះអង្គបំបួសនាក្នុងកម្លុងរាជគ្រឹះនោះមួយម៉ឺន ព្រះបាទស្រីសុទ្ធោទនមហារាជប្រើទៅនោះមួយម៉ឺន ព្រះអង្គបំបួសទាំងអស់ត្រូវជាពីរម៉ឺនហោង ។ ឧទាយិអាមាត្យបានបួសរួចហើយ ទ្បើងព្រះនាមជាព្រះមហាឧទាយិត្ថេរ ទើបភ្ញាក់ស្មារតីគិតពិចារណាថា ឱ អញអើយ អញឥតគំនិត ឥតស្មារតីអ្វីមាល្បាយអេះព្រះមហាក្សត្រា ព្រះអង្គប្រើអញមកនិមន្តព្រះរាជបុត្រលោក ម្ដេចឡើយក៏អញបានជាមកបួស បើបួសហើយ ម្ដេចឡើយក៏មកនៅស្ងៀមព្រងើយកន្តើយដូច្នេះហ៎ ឱអញអើយ ចំណេរទៅឯភ្នែកហើយយល់ថានឹងត្រូវព្រះរាជទណ្ឌនៃព្រះមហាក្សត្រានោះទៀងប្រាកដ មិនទេឡើយ ក៏ថាបើដូច្នោះអញនឹងនៅយូរឯណាបានឡើយ គួរអញនឹង

Websites: WatKhemaraRatanaram.org or WatKhmers.org

ចូលទៅក្រាបថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយសូមអារាធនានិមន្តព្រះអង្គទៅឆាប់ក៏បានអេះ ។ ព្រះមហាឧទាយិត្ថេរ គិតពិចារណាស្រេច នូវប្រការអម្បាលណោះហើយ ក៏ចូលទៅក្រាបថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយពុំហ៊ានទូលស្មោះឆ្ពោះត្រង់ណោះឡើយ ទូលធ្វើជាហេតុបន្តិចថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ រីខែនេះជាកាលខែហេមន្តរដូវ រីផ្លូវនឹងទៅកាន់កបិលពស្ដុបុរី ស្រីមហានគរនោះសោត ស្រណុកសុខសប្បាយពណ្ណរាយក្រៃពេក ។ រីអស់ថ្មើរព្រៃផងទាំងឡាយសោត សឹងដើរគ្រាច់រង្គាត់ ច្រវាត់ទៅមករកបរបាញ់ ហើយអុជភ្លើងព្រៃដ៏មានប្រឆេះនោះពិដោរឈ្មុយឈ្ងប់ ត្រឡប់ឡើងទៅនាកណ្ដាលអាកាសវេហាស៍ មិនប៉ុន្តែម្ល៉ោះសោត រីឈើព្រៃព្រឹក្សាលតាវល្លិផងទាំងឡាយ សឹងដ៏ដុះជាជួររៀងរាយដោយនូវពណ៌ទីទៃៗ សឹងមានដើមនោះល្អ សឹងដ៏ល្វតលាស់លំពង់ដ៏ទ្រង់នូវមែកសាខាបុប្ផាសន្លឹក អធិកនីទៅនូវផ្លែផ្កានោះដ៏រីកស្គុសស្គាយ ពណ្ណរាយល្អបីដូចអ្នកយកសំពត់ទុក្កូលពស្ត្រ មកគ្របអំពីចុងសំយុងដល់ដើម រីកេសរផ្កាផងទាំងឡាយនោះសោត ដ៏

ពិដោរឈ្វេងត្រឡប់ អប់ឡើងទៅដល់នាកណ្ដាលអាកាស បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ថាបើស្ដេចលីលាយាត្រាទៅ ឥឡូវនេះហើយ សមនឹងជាសុខសប្បាយ រីអស់ភិក្ខុសង្ឃអង្គអរហន្តាខីណាស្រពផងទាំងឡាយនោះ ក៏ច្រើនពេក បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ រីផ្លូវនឹងទៅកាន់កបិលពស្ដុបុរីស្រីមហានគរ ក៏សឹងជាសុខសប្បាយក្រៃពេកហោង ។

កាលព្រះដ៏មានបុណ្យ ព្រះអង្គស្ដាប់ពាក្យព្រះមហាឧទាយិត្ថេរទូលដូច្នោះក្ដី ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថា វោ ឥឡូវនេះសម្ដេចព្រះវរបិតា អ្នកប្រើមហាឧទាយិត្ថេរ មកនិមន្តអញតថាគតហើយហ:ហ្ន៎ ថាបើដូច្នោះគួរអញតថាគត នឹងទៅកាន់កបិលពស្ដុបុរីស្រីមហានគរបវររាជដ្ឋាន ឲ្យបានដល់យល់សម្ដេចព្រះវរបិតាអញតថាគតហោង ។ ព្រះដ៏មានបុណ្យព្រះអង្គទ្រង់ព្រះចិន្តាពិចារណានូវប្រការអម្បាលណោះហើយ ទើបព្រះអង្គមានព្រះបន្ទូល នឹងព្រះមហាឧទាយិត្ថេរថា ម្នាលឧទាយិត្ថេរអើយ ថាបើដូច្នោះ ចូរបាទៅប្រាមប្រាប់បង្គាប់អស់ភិក្ខុផងទាំងឡាយ ឲ្យប្រដាប់ប្រដាអាត្មាទីទៃៗ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យឆាប់ ៗ កុំបីយូរឡើយ ។

ព្រះមហាឧទាយិត្ថេរ ស្ដាប់ព្រះបន្ទូលថ្លៃវិសេស នៃព្រះដ៏មានបុណ្យហើយ ក៏ទៅប្រាមប្រាប់ភិក្ខុផងទាំងឡាយថា ម្នាលភិក្ខុទាំងឡាយអើយ ឥឡូវនេះព្រះដ៏មានបុណ្យ ព្រះអង្គស្ដេចនឹងលីលាទៅកាន់កបិលពស្ដុបុរីស្រីមហានគរនោះ ឲ្យអស់ភិក្ខុទាំងឡាយ រៀបប្រដាប់ប្រដាអាត្មាទីទៃៗ កុំបីយូរឡើយ ។ កាលនោះ រីអស់ភិក្ខុផងទាំងឡាយ ស្ដាប់ពាក្យព្រះមហាឧទាយិត្ថេរដូច្នោះហើយ សឹងដ៏ប្រដាប់ប្រដាអាត្មាទីទៃ ៗ ស្រេចហើយនែ ទើបព្រះដ៏មានបុណ្យព្រះអង្គលីលាយាត្រាទៅអំពីនគររាជគ្រឹះបុរី រៀងរាបដរាបទៅដល់កបិលពស្ដុបុរីស្រីមហានគរ ដោយនូវព្រះដំណើរជាបឋម មួយអន្លើនិងអស់ភិក្ខុសង្ឃ អង្គអរហន្តាខីណាស្រព ផងទាំងឡាយនោះប្រមាណពីរម៉ឺនជាបរិវារ មានព្រះមហាឧទាយិត្ថេរឯង ជាមគ្គុទេសក៍ដ៏វិសេសតែងនឹងនាំផ្លូវព្រះអង្គហោង ។

តតោ សក្យរាជានោ មយំ ឥមំ សិទ្ធត្ថកុមារំ អម្ហាកំ ញាតិសេដ្ឋំ បស្សិស្សាមាតិ សន្និបតិត្វា ។ បពិត្រអើយ ពួដ៏កាល

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះ រីអស់ស្តេចសាក្យរាជផងទាំងឡាយ ដ៏ជាព្រះញាតិនឹងព្រះបាទស្រីសុទ្ធោទនមហារាជនោះ ៨ ម៉ឺន ៩ ពាន់ មានព្រះបាទស្រីសុទ្ធោ-ទនឯងជាប្រធាន សឹងដ៏មានចំណង់ នឹងចង់យល់ព្រះដ៏មានបុណ្យនោះ ក៏មកជំនុំពិចារណាស្វែងរកឋានលំនៅ ឲ្យជាឧត្តមសមគួរនឹងព្រះអង្គគង់ ទើបមកកត់សំគាល់យល់តែឋានថៅនិគ្រោធកុមារនោះឯង ដ៏សុខសប្បាយ គាប់ចិត្តប្រពៃហើយនៃ ទើបស្តេចឲ្យចូកថាំងជម្រះលុបថ្លុកជង្ហុក ផ្អៀងរលៀងអំបែងចេះ អំបែងចានគ្រួសរវានផង់ផុយធូលីដីខ្សាច់ប្រាបឲ្យរាបស្មើ ធ្វើឲ្យប្រពៃ ស្រេចហើយនៃ ទើបឲ្យក្រាលនីទៅ នូវកម្រាលចៀមចំព្រៃព្រំ ដ៏ទន់ល្វន់ ប្រដាប់ស្រេចហើយ ទើបឲ្យទៅនិមន្តព្រះដ៏មានបុណ្យ ព្រះអង្គលីលាទៅគង់ស្រេចបរិបូណ៌ព្វដ៏ក្សិណនោះពុំយូរឡើយ ។ រីអស់ស្តេច សាក្យរាជផងទាំងឡាយ ហេតុមានកំណើតនោះសឹងមានះរឹងត្អឹងមហិមា ហេតុតែដ៏ជាស្តេចធំសមនូវយសសម្បត្តិនោះច្រើន មកគិតពិចារណាថា ព្រះសិទ្ធាថិកុមារនោះ គាត់ក្មេងក្រៃលែង នឹងអស់យើងទាំងឡាយអម្បាលណោះ គាត់ជាប្អូន ជាកូនក្មួយ ជាចៅយើងទេក្ងរ ម្តេចឡើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

យើងនឹងទៅសំពះគាត់នោះយល់ពុំគួរឡើយ ។ រីអស់ស្តេចសាក្យរាជខ្លះ ឮហើយឆ្លើយថា ទេមិនសំពះគាត់ឯណាក៏បាន មិនដូចគាត់ជាគ្រហស្ថឡើយ គាត់នេះជាអ្នកបួស រីធម្មតាជាអ្នកបួសនោះចាស់ក្តីទោះក្មេងក្តី ត្រូវតែសំពះគាត់ដដែលឯងអេះ ថាបើអស់យើងទាំងអម្បាលណេះមិនសំពះគាត់ហើយ តើគាត់មិនថាយើងមានអំនួតទៅហើយហ: ។ អ្នកខ្លះឮហើយឆ្លើយថា អើបើដូច្នោះអ្នកលងគំនិតមើលតើយើងនឹងគិតធ្វើម្តេចឲ្យសមគួរនឹងគាត់ហ: ។ ស្តេចសាក្យរាជខ្លះឮហើយឆ្លើយថា ទេគំនិតនោះវានឹងក្រអ្វីអ្នកទាំងឡាយ វាងាយទេ ។ អ្នកខ្លះឮហើយឆ្លើយថា អើបើដូច្នោះអ្នកគិតទៅលងមើលអ្នក ថាបើអ្នកប្រើអញគិតហើយ អញគិតក៏បានអេះ នាអញគិតនោះមាន គឺឲ្យរកកុមារប្រុស-ស្រី ឲ្យមានដៃកាន់នីទៅនូវទានធូបគន្ធមាលាភ្ញីផ្កា ស្លាម្លូស្រេចហើយ យើងនឹងឲ្យដំណើរទៅមុន ហើយឱ្យបូជាថ្វាយបង្គំប្រណម្យគាត់ រីអស់យើងសោត សឹងដ៏ដើរតាមដោយចន្លោះលង្វែងវផ្សំប្រទ្បំ នៅក្នុងក្មេងផងទាំងឡាយនោះ តែយើងកុំអាលសំពះគាតឡើយ កាលបើស្តេចសាក្យរាជផងទាំងឡាយ ជំនុំនឹងគ្នាព្រមល្មម

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រេចហើយ ក៏ធ្វើដូចព្រះចិន្តាគិតនោះឯងហោង ។

ភគវា តេសំ អជ្ឈាសយំ ឱលោកេត្វា ន មំ ញាតយោ វន្ទន្តិ ។ រីព្រះដ៏មានបុណ្យ ព្រះអង្គដឹងអធ្យាស្រ័យនៃចិត្តអស់ព្រះញាតិផងទាំងឡាយ មិនថ្វាយបង្គំប្រណម្យព្រះអង្គដូច្នោះហើយ ក៏ស្តេចទ្រង់ព្រះចិន្តាពិចារណាថា ឱ ! ឥឡូវនេះអស់ព្រះញាតិអញតថាគតនេះមិនទាន់ដឹងថា អញតថាគតបានត្រាស់ជាព្រះពុទ្ធទេហ្ន៎ ក៏ថាបើដូច្នេះ អញតថាគតនឹងសំដែងនូវកំណើតប្រាជ្ញាអរិយសប្បុរស ឲ្យប្រាកដដូចព្រះពុទ្ធអំពីបុរាណរៀងមក ឲ្យស្តេចសាក្យរាជទាំងឡាយ ថ្វាយបង្គំប្រណម្យអញតថាគត ក្នុងកាលឥឡូវនេះឯងហោង ។ ព្រះដ៏មានបុណ្យព្រះអង្គទ្រង់ព្រះចិន្តាពិចារណា ស្រេចនូវប្រការណោះហើយ ទើបស្តេចចូលចតុត្ថជ្ឈានអភិញ្ញាសមាបត្តិ ហោះផ្លោះឡើងទៅនាកណ្តាលអាកាស ដ៏ឱភាសនូវពន្លឺរស្មីនោះរុងរឿងភ្លឺព្រោងព្រាយ ពណ្ណរាយឆាឆាយក្ងួចគ្រលួចឡើងចេញអំពីព្រះបាទទាំងពីរ យល់ដូចផង់ផុយធូលីដីខ្សាច់ គិតដ៏ប្រាយរាយចុះមកលើព្រះកេសស្តេចសាក្យរាជទាំងឡាយ ប្រហែលដូចកាល

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គធ្វើយមកបាដិហារិយ៍ ឮដ៏នាដើមគណ្ឌាម្ពព្រឹក្ស អធិកនូវព្រះរស្មី ឲ្យដំបូន្មានអន្សត្ថិរិយនោះឯងហោង ។

តទា សុទ្ធោទនមហារាជា តំ អច្ឆរិយំ ទិស្វា អាហ ។ ឮដ៏កាលនោះព្រះបាទស្រីសុទ្ធោទនមហារាជ ដ៏ជាស្តេចព្រះវរបិតាធិរាជយល់ជាអស្ចារ្យប្រាកដដូច្នោះក្ដី ពុំអាចដើម្បីនឹងទប់ទល់តម្កល់ព្រះអង្គបានឡើយ សឹងដ៏លើកកម្បង់អញ្ជលីដាក់លើព្រះកេស វិសេសថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយសរសើរគុណបុណ្យព្រះសម្ភារបារមីថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ កាលនោះមានមហាឫសីមួយ ឈ្មោះកាឡទេពិលជដិលតាបស អ្នកមានរិទ្ធិអានុភាពនោះច្រើនក្រៃលែង នាកាលសម័យថ្ងៃព្រះអង្គកើតនោះឯង អស់មេទំផងទាំងឡាយ វានាំព្រះអង្គចេញមក ប្រយោជន៍ដើម្បីនឹងឲ្យនមស្ការថ្វាយបង្គំ សូមពរអំពីកាឡទេពិលជដិលមហាឫសីនោះ ក៏ព្រះអង្គមិនថ្វាយបង្គំឡើយ វិលប្រែក្រឡាប់ឡើងទៅគង់លើក្បាលមហាឫសីនោះវិញហោង ។ បពិត្រអើយ ខ្ញុំយល់ជាអស្ចារ្យប្រាកដដូច្នោះហើយ ខ្ញុំថ្វាយបង្គំប្រណម្យព្រះអង្គជាប្រថមហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

មួយសោត កាលថ្ងៃច្រត់ព្រះនង្គ័លជាមង្គលអំពល់នូវសុខសួស្តីប្រ-សើរ កបនូវដំណើរឫក្សពារ ពេលាឆាយាប្រពៃនាថ្ងៃនោះឯង មេនំផងវានាំព្រះអង្គទៅផ្ទំលើគ្រែ ក្រឡាព្រះបន្ទំបរមសុខសួស្តី នាក្រោមម្លប់ជម្ពូព្រឹក្សនោះ។ វិស្រមោលជម្ពូព្រឹក្សនោះសោត ពុំជ្រេជ្រៀងល្អៀងទៅដោយនូវដំណើរព្រះអាទិត្យនោះឡើយ ខ្ញុំយល់អស្ចារ្យកាលនោះ ខ្ញុំថ្វាយបង្គំប្រណម្យព្រះអង្គជាគំរប់ពីរដង ។ ហើយឥឡូវនេះវិញសោតទៀត អំពីមុនមក ខ្ញុំពុំដែលបានយល់នូវយមកបាដិហារិយ៍ត្រកាលជាអស្ចារ្យដូច្នោះទេ ទើបខ្ញុំថ្វាយបង្គំព្រះអង្គ ជាគំរប់បីដងហោង ។ កាលណាបើព្រះបាទស្រីសុទ្ធោទនមហារាជ លើកកម្បង់អញ្ជលីថ្វាយបង្គំប្រណម្យហើយ សូម្បីស្តេចសាក្យរាជឯណាមួយនឹងទប់ទល់តម្កល់ចិត្តរឹងត្អឹង មិនព្រមថ្វាយបង្គំប្រណម្យព្រះអង្គនោះឥតអង្គឹមានឡើយ ។

និសិន្នេ បន ភគវតិ សិក្ខាប្បត្តោ ញាតិសមាគមោ អហោសិ ។ សព្វេបិ ឯកគ្គចិត្តា ហុត្វា និសីទឹសុ ។ វិសម្តេចព្រះស្រីសពេជ្ញតាញាណ ព្រះអង្គឲ្យដំបូន្មានអស់ព្រះញាតិផងទាំងឡាយ

ឲ្យបានថ្វាយបង្គំប្រណម្យ នូវប្រការអម្បាលណោះហើយ ទើបព្រះអង្គហោះចុះមកអំពីកណ្តាលអាកាស ស្តេចមកគង់លើគ្រែបវរពុទ្ធា-សនាក្រទ្បាសម្រាប់ គិតដ៏អ្នកប្រដាប់ក្រាលនូវកម្រាលផងប្រពៃ ឰដ៏កណ្តាលជំនុំអស់ព្រះញាតិទាំងទ្បាយ សឹងលុះដោយនូវជំបូន្មានព្រះអង្គក្នុងកាលនោះហោង ។ ឰដ៏កាលនោះ វីអស់ស្តេចសាក្យរាជផងទាំងទ្បាយ សឹងដ៏មានព្រះរាជហឫទ័យនោះ ត្រេកអរសាទរព្រមជាមួយនឹងគ្នា ។ អណ្តាប់នោះ មហាមេឃឯង ក៏បង្អុរនូវភ្លៀងសួគ៌មួយឈ្មោះបោក្ខរព័សិ ជាអស្ចារ្យកណ្តាលជំនុំព្រះញាតិផងទាំងទ្បាយ ថាបើអ្នកឯណាចង់ទទឹក អើក៏ភ្លៀងនោះទទឹក ថាបើអ្នកឯណាពុំចង់ទទឹក អើក៏ភ្លៀងនោះពុំជិតដល់សុរិលអ្នកនោះដល់តិចទ្បើយ ។

តំ ទិស្វា សព្វេ អច្ឆរិយព្ភុតជាតា អហេសុំ ។ កាលនោះ អស់មហាជនផងទាំងទ្បាយ យល់អស្ចារ្យប្រាកដកើតមានដូច្នោះហើយ សឹងសរសើរព្រះបារមីនៃព្រះដ៏មានបុណ្យថា ឱ! ព្រះពុទ្ធអើយ ព្រះអង្គមានព្រះបារមីរិទ្ធីអានុភាពច្រើនអ្វីមាល្បាយអេះ ភ្លៀង

Websites: WatKhemaraRatanaram.org or WatKhmers.org

បង្អុរចុះមកអំពីកណ្តាលអាកាស ធ្លាក់ចុះទៅនាកណ្តាលជំនុំ ព្រះញាតិផងទាំងឡាយ អ្នកឯណាចង់ទទឹក អើក៏ភ្លៀងនោះទទឹក អ្នកឯណាពុំចង់ទទឹក អើក៏ភ្លៀងនោះពុំទទឹកឡើយ ដូចទឹកធ្លាក់ទៅលើស្លឹកឈូកហោង ។

តេ ភិក្ខូ ធម្មសភាយំ កថំ សមុដ្ឋាបេសុំ ។ ឰដ៏កាលនោះ រីអស់ភិក្ខុផងទាំងឡាយបបួលគ្នាទៅជំនុំ ឰដ៏ធម្មសភាសាលាថា អាវុសោ ម្នាលភិក្ខុផងទាំងឡាយអើយ រីព្រះដ៏មានបុណ្យជាម្ចាស់យើងនេះ ព្រះអង្គមានឫទ្ធីអានុភាពច្រើនជាអស្ចារ្យ ឰដ៏លោកនេះ អ្វីមាល្បាយអេះ អំពីមុនមកពុំដែលយល់ដូច្នេះ ក៏ឥឡូវនេះ មហាមេឃឯង បង្អុរនូវភ្លៀងបោក្ខរព័សិជាអស្ចារ្យនាកណ្តាលជំនុំព្រះញាតិនោះឯង ។ តំ សុត្វា សត្ថា កាយនុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសន្នាតិ បុច្ឆិត្វា ។ រីពត៌មានអស់ភិក្ខុផងទាំងឡាយនោះ មិនបាត់ស្ងាត់ ប៉ុន្តែប្រលុងក្នុងធម្មសភាសាលានោះឡើយ ក៏ឮជ្រួតជ្រាបដរាបទៅដល់ព្រះស្រោត្រទិព្វថ្លៃ នៃព្រះដ៏មានបុណ្យព្រះអង្គជ្រាបដោយនូវអស់អាថ៌សេចក្តី នៃភិក្ខុផងទាំងឡាយនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ ស្តេចទ្រង់ព្រះចិន្តាពិចារណាថា ៖ ឥឡូវនេះអស់ភិក្ខុផង ទាំងឡាយបានបប្ចូលគ្នាទៅជំនុំ នៅនាធម្មសភាសាលា សឹងស្រដី សរសើរអំពីប្រាជ្ញាបារមីនៃអញតថាគតនេះហ្ន៎ ក៏ថាបើដូច្នោះ អញ តថាគតនឹងទៅស្តាប់ជំនុំនៃភិក្ខុផងទាំងឡាយបន្តិចក៏បានអេះ ថាបើ អញតថាគតមិនទៅស្តាប់ជំនុំនៃភិក្ខុសង្ឃផងទាំងឡាយនេះហើយ ក៏ នាកាលអញតថាគតយោនយកកំណើត កើតជាពោធិសត្វមុនមួយ ព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរឈ្មោះថាមហាវេស្សន្តរនោះ នឹង កំបាំងបាត់ស្វាត់ពុំឆ្ងាយទូលាយទៅឯភ្នែកឡើយ ។ ព្រះដ៏មានបុណ្យ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណា នូវប្រការអម្បាលណោះហើយ ទើប ស្តេចលីលាមកអំពីព្រះសុគន្ធកុដីស្រីមហាវិហារ ទៅកាន់ធម្មសភា សាលាដ៏មានព្រះដំណើរសីហនាទគគាតឥតភ្លឹកបីដូចកេសររាជសីហ៍ ចេញអំពីគុហាមាស ឰដ៏កណ្តាលពពួកម្រឹគគណនិករផងទាំងឡាយ នោះមានប្រការម្តេចមិញ ក៏ស្តេចទៅគង់លើគ្រែអាសនា ក្រឡា សម្តេច មានឰដ៏កណ្តាលជំនុំចតុព្វិធបរិសទ្យទាំង ៤ ចំពូក ព្រះអង្គ មានព្រះបន្ទូល ប្រកបនូវព្រះសូរធូរជ្រៅជ្រះស្រឡះពីរោះស្មោះស្មើ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដណ្ដឹងទៅកាន់ភិក្ខុទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ នាអ្នកទាំងឡាយមកជំនុំគ្នានៅនេះ តើស្រដីដោយនូវពាក្យអ្វីឆោឡោពួជំធម្មសភាសាលានេះ ក៏មិនដោះដាលត្រអាលឡើងទៅរកចម្រើនមេត្តាភាវនាវិបស្សនាកម្មដ្ឋាន ឲ្យបានមគ្គផលដល់សម្បត្តិព្រះនិព្វានដ៏ជាឋានពំនាក់អាត្មាទីទៃៗ ហ៎ុះ ។

ឥមាយ ឆាមាតិ វុត្តេ ទើបអស់ភិក្ខុទាំងឡាយ ក្រាបថ្វាយបង្គំប្រណម្យទូលថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ រីអស់យើងខ្ញុំមកជំនុំគ្នានៅនាធម្មសភាសាលានេះ មិនគឺនឹងស្រដីនូវឥត្ថីភាពបុរិសភាព ឲ្យជាមន្ទិលក្នុងព្រះសាសនាព្រះអង្គនេះឡើយ សឹងតែស្រដីសរសើរដំណើរ អំពីព្រះបារមីថ្លៃនៃព្រះអង្គឯងត្បិតមានភ្លៀងបោក្ខរព័សិបង្អុរចុះមកជាអស្ចារ្យ ដូចន័យព្រះអង្គជ្រាបក្នុងព្រះរាជហឫទ័យស្រាប់នោះឯង ។ ព្រះដ៏មានបុណ្យព្រះអង្គជ្រាបហើយ មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយអើយ នាភ្លៀងបោក្ខរព័សិនេះ មិនតែឥឡូវនេះឡើយ នាកាលតថាគតយោនយកកំណើតជាពោធិសត្វមួយអង្គ ទ្រង់ព្រះនាមករណ៍បវរ ហៅថាមហា

Websites: WatKhemaraRatanaram.org or WatKhmers.org

វេស្សន្តរនោះ ក៏មហាមេឃឯង បង្អុរនូវភ្លៀងបោក្ខរព័ស៌ជាអស្ចារ្យ ឮដ៏កណ្តាលជំនុំព្រះញាតិផងទាំងឡាយនោះ ក៏អស្ចារ្យក្រៃអេះ ត្បិតប្រាជ្ញាមិនទាន់ចាស់ បារមីពុំទាន់ទុំ ក៏ឥឡូវនេះតថាគតបានត្រាស់ប្រាជ្ញាសពេ៌ជ្ញូតាញាណជាព្រះពុទ្ធហើយ វិស័យដូចព្រះពុទ្ធអំពីមុនរៀងមក តែងនឹងមានបារមីដូច្នេះឯង ។

*វត្វា តុណ្ហី អហោសិ* ។ ព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋ ពីរព្រះឱស្ឋដូច្នោះហើយ ព្រះអង្គគង់ស្ងៀមទៅវិញហោង ។

*តេហិ យាចិតោ អតីតំ អាហរិ* ។ អណ្តាប់នោះអស់ភិក្ខុផងទាំងឡាយ ដឹងហេតុព្រះដ៏មានបុណ្យ នូវប្រការអម្បាលណោះហើយ សឹងមានចំណង់នឹងចង់ស្តាប់ព្រះធម៌វិសេសទេសនានោះ ហើយទើបនាំគ្នាលត់ជង្គង់ លើកកម្បង់អញ្ជលី ដាក់លើសិរសាអាត្មាភាព ក្រាបថ្វាយបង្គំប្រណម្យទូលថា *ភន្តេ ភគវា* បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ព្រះអង្គមានព្រះបន្ទូលអម្បាញ់មិញនោះថា នាកាលព្រះអង្គយោនយកកំណើតកើតជាព្រះពោធិសត្វ ១ ព្រះអង្គ ទ្រង់ព្រះនាមព្រះមហាវេស្សន្តរនោះ អស់យើងខ្ញុំគ្រាន់តែបានឮព្រះបន្ទូលអម្បាល

Websites: WatKhemaraRatanaram.org or WatKhmers.org

ណោះ  រីនឹងដឹងជាតិសន្តានកន្លងរំលងទៅហើយនោះ  យើងខ្ញុំពុំទាន់ដឹងឡើយ  បពិត្រព្រះដ៏មានបុណ្យអើយ  សូមព្រះអង្គយកព្រះប្រាជ្ញាទិព្វវិសេសមួយឈ្មោះ  បុព្វេនិវាសានុស្សតិញ្ញាណ  ទៅឱបក្រសោបអស់ធម៌ទាំងឡាយ  ដែលកន្លងរំលងទៅហើយនោះនាំយកមកសម្តែង  ថ្លែងទេសនាជាសណ្តាប់  ប្រាប់អស់យើងខ្ញុំទាំងអម្បាលណោះហោង ។

ព្រះដ៏មានបុណ្យព្រះអង្គជ្រាបហើយ  ព្រះអង្គនឹងនាំនូវព្រះធម៌វិសេសទេសនា  ឲ្យជាសណ្តាប់ប្រាប់ព្រះវរបិតា  នូវអស់ព្រះញាតិផងទាំងពួង  នូវអស់ភិក្ខុសង្ឃអង្គអរហន្តាខីណាស្រពផងទាំងឡាយឲ្យឆ្ងាយកន្លងរំលងទៅនោះ  ក៏ព្រះអង្គបើកព្រះឱស្ឋវត្តបន្ទូល  ដ៏មានព្រះសូរនោះមូលក្រាងក្រអៅ  ជ្រៅជ្រះស្រឡះពីរោះ  ឧបមាបីដូចសំឡេងព្រហ្ម ទ្រង់សូត្រនូវបទបាលីដូច្នេះថា  អតីតេ  ភិក្ខវេ  សិវិរដ្ឋេ  ជេតុត្តរនគរេ  សិវិមហារាជា  នាម  រជ្ជំ  ការេន្តោ  សញ្ជយំ  នាម  បុត្តំ  បដិលភិ ។

ភិក្ខុអើយ  នាកាលភព្វន្តរខណ្ឌកប្បកល្បខាំងកំបាំងបាត់

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្វាត់ កន្លងរំលងទៅហើយនោះ កាលនោះមានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់នាមករណ៍បវរថា ព្រះបាទសិរិមហារាជ សោយរាជ្យសម្បត្តិបិតនៅមួយអន្លើនឹងព្រះរាជទេពី ស្រីព្រះស្នំក្រមការបរិពារផងទាំងឡាយ នៅឰដ៏កំឡុងស្រុកជេតុត្តរនគរ ។ ភិក្ខុអើយ រីព្រះមហាក្សត្រាធិរាជនោះសោត មានព្រះរាជបុត្រមួយ ព្រះនាមថៅសញ្ជ័យកុមារ លុះថៅសញ្ជ័យកុមារនោះចំរើនព្រះជន្មឡើងបាន ១៦ វស្សាបរិបូណ៌ហើយ ទើបព្រះបាទសិរិមហារាជ ស្តេចឲ្យទៅនាំព្រះរាជបុត្រីស្រីរត្នកញ្ញា នៃព្រះបាទមទ្ទរាជអំពីមាតុលនគរ ព្រះនាមព្រះនាងសុបារសុប្បតី យកមកផ្សំនឹងថៅសញ្ជ័យកុមារ អភិសេកឱ្យសោយរាជ្យសម្បត្តិ ស្នងគ្រងប្រពៃណីអំពីបុរាណ ។ សម្តេចព្រះវររាជបិតាធិរាជ តម្កល់ព្រះនាងឱ្យជាឧត្តម កន្លងក្រៃលែងអស់ស្រីព្រះស្នំផងទាំងឡាយ ១ ម៉ឺន ៦ ពាន់នោះឯងហោង ។

តស្សាបិ អយំ បុព្វបយោគោ ។ ឥតោ ហិ ឯកនវុតិ-កប្បាវសានេ វិបស្សី ឆាម សត្ថា លោកេ ឧទបាទិ ។ បពិត្រអើយ នេះនឹងស្រដីសរសើរដំណើរដំណាល កាលនាងសុបារសុប្បតី

Websites: WatKhemaraRatanaram.org or WatKhmers.org

ទេវី សាងបារមីអំពីជាតិមុន ឱ្យប្រាកដប្រកបជួបចូល មិត្តមូលមក និយាយបទងចុងនេះវិញ ។ នាកាលអំណើះក័ល្បទាំងឡាយកន្លងរំលងទៅហើយ រាប់ថយក្រោយទៅបាន ៩១ កល្ប រៀងរាបដរាបមកដល់ភទ្ទកល្បយើងនេះ កាលនោះមានព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរឈ្មោះព្រះពុទ្ធវិបស្សី សិរីសម្មាសម្ពុទ្ធ ស្តេចបានត្រាស់សពេជ្ញតាញាណឰដ៏លោកនេះ ព្រះអង្គនាំព្រះធម៌វិសេសទេសនាប្រោសសត្វផងទាំងឡាយ ឱ្យបានមគ្គផលដល់សម្បត្តិនិព្វាន ដ៏ជាឋានក្សេមប្រសើរ ហើយស្តេចគង់នៅឰដ៏ព្រៃខេមមិគទាយពន ស្តេចអាស្រ័យយកព្រះបិណ្ឌបាត សង្វាតសន្តោសប្រោសសត្វ ផងទាំងឡាយ នៅឰដ៏ស្រុកពន្ធុមតី ស្រីមហានគរបវររាជដ្ឋាន ។

តទា ពន្ធុមតីនគរេ ពន្ធុមោ នាម រាជា រជ្ជំ ការេសិ ។ តស្មឹ ពន្ធុមតីនគរំ ឧបនិស្សាយ ខេមមិគទាយេ វិហរន្តេ តស្មឹ កាលេ ឯកោ រាជា រញ្ញោ ពន្ធុមស្ស អនគ្ឃេន ចន្ទនសារេន សទ្ធឹ សតសហស្សគ្ឃនិកំ សុវណ្ណមាលំ បេសេសិ ។ ឰដ៏កាលនោះ មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាម

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបាទពន្ធុមរាជ សោយរាជសម្បត្តិ បិតព្វដ៏ស្រុកពន្ធុមតីស្រីមហានគរនោះ ។ កាលនោះសោត មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គទៀត ជាស្តេចទ្រង់ព្រះនាមព្រះបាទសាមន្តរាជ ស្តេចឲ្យរាជអាមាត្យមួយនាក់យកសុពណ៌មាលាដ៏មានតម្លៃនោះមួយសែនតម្លឹង មួយអន្លើនូវខ្លឹមច័ន្ទន៍ សឹងដ៏មានតម្លៃនោះច្រើន ឲ្យនាំមកថ្វាយព្រះបាទពន្ធុ-មរាជ ។ រីព្រះបាទពន្ធុមរាជសោត ស្តេចមានព្រះរាជបុត្រីស្រីកញ្ញានោះពីរព្រះអង្គ ហើយទ្រង់ព្រះរាជទានខ្លឹមច័ន្ទន៍នោះ ទៅព្រះរាជបុត្រីដ៏ជាច្បង រីសុពណ៌មាលាមាសនោះ ស្តេចព្រះរាជប្រទានឱ្យទៅព្រះរាជបុត្រីដ៏ជាប្អូន ។ ឯព្រះរាជកុមារីទាំងពីរអង្គនោះសោត មកគិតពិចារណានឹងគ្នាថា នាងអើយរីខ្លឹមចន្ទន៍និងសុពណ៌មាលាមាសនេះសម្តេចព្រះវរបិតា អ្នកប្រទានមកយើងនេះ ឯគ្រឿងប្រដាប់ទាំងនេះមិនគួរបីយើងនឹងប្រដាប់សម្រាប់អាត្មានៃយើងឡើយ ថាបើដូច្នោះយើងនឹងទៅថ្វាយបូជាព្រះដ៏មានបុណ្យវិញ នោះជាគុណបុណ្យប្រសើរពេកហោង ។ រីព្រះរាជកញ្ញាទាំងពីរ គិតពិចារណានូវប្រការអម្បាលណោះហើយក្តី ក៏ចូលទៅក្រាបទូលសម្តេចព្រះវររាជបិតាថា

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រសម្តេចព្រះវរបិតា នៃយើងខ្ញុំទាំងពីរអើយ នាខ្លឹមច័ន្ទន៍និង សុពណ៌មាលាមាសនោះ យើងខ្ញុំម្ចាស់ទាំងពីរនេះ ចង់យកទៅថ្វាយ បូជាព្រះដ៏មានបុណ្យវិញ ។ រីព្រះមហាក្សត្រាធិរាជ ស្តាប់ពាក្យនាង កញ្ញាទាំងពីរ នូវប្រការអម្បាលនោះហើយ ស្តេចមានព្រះរាជហឫទ័យ នោះពេញនូវក្តីអំណរ អរទទួលយកពាក្យព្រះរាជធីតា ហើយទ្រង់ អនុមោទនាថា សាធុ ៗ ពីរោះ ៗ ពេក ថាបើដូច្នោះចូរនាងយកទៅ ថ្វាយបូជាព្រះពុទ្ធវីបស្សីនោះ ជាបុណ្យប្រសើរក្រៃពេកហោង ។ រីព្រះ រាជកញ្ញាដ៏ជាច្បងនោះ ត្រាស់ប្រើរាជអាមាត្យមួយ ឲ្យយកខ្លឹមច័ន្ទន៍ នោះ ទៅបុកឲ្យល្អិតជាផង់ធូលីប្រពៃហើយនៃ ឲ្យដាក់ក្នុងប្រអប់មាស ឲ្យស្រីសាវជៃមួយ ជាអ្នកកំណាន់កាន់ប្រអប់មាសនោះ ។ រីឯនាង កញ្ញាដ៏ជាប្អូននោះសោត ក៏ឲ្យយកសុពណ៌មាលាមាសឲ្យទៅ ជាង រចនាធ្វើជាគ្រឿងប្រដាប់ព្រះឱរា ហើយទុកក្នុងប្រអប់មាសប្រពៃ ហើយនៃ ឲ្យស្រីសាវជៃមួយជាអ្នកកំណាន់កាន់រក្សាស្រេចហើយ ទើប ព្រះរាជកញ្ញាទាំងពីរ លីលាយាត្រាចេញអំពីប្រាសាទព្រះរាជមន្ទីរមួយ អន្លើនូវអស់បរិវារស្រីផងទាំងឡាយនោះច្រើន ស្មោះឆ្ពោះមុខទៅកាន់

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រៃខេមមិគទាយពនមហាវិហារនោះហោង ។ រីព្រះរាជកញ្ញាដ៏ជាច្បង នោះ នាងប្រាផ្កាប្រអប់មាសខ្លឹមច័ន្ទន៍ ចូលទៅថ្វាយបូជា ព្រះពុទ្ធវិបស្សី ហើយនាងលាបស្រលាបអស់ទាំងគ្រែក្រឡា បន្ទំបរមសុខស្វស្តិក្នុងព្រះសុគន្ធកុដិនោះ រីសំណល់សល់អំពីនោះសោត នាងក៏លាបស្រលាបអស់ទាំងសសរស្តម្ភ ព្រះសុគន្ធកុដីស្រីមហាវិហារនោះ ទើបនាងធ្វើប្រណិធាន សូត្រជាបាទព្រះគាថាដូច្នេះថា ៖

ឯសា ចន្ទនចុណ្ណេន បូជា តុម្ហេសុ មេ កតា
តុម្ហាធិសស្ស ពុទ្ធស្ស មាតា ហេស្ស អនាគតេតិ ។

ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ហេតុតែតេជៈផលានិសង្សនៃអញខ្ញុំម្ចាស់ យកលំអិតខ្លឹមច័ន្ទន៍មកថ្វាយបូជាព្រះអង្គនេះ លុះអនាគតកាលទៅឯភ្នែក ខ្ញុំសូមឲ្យបានជា ព្រះកន្លោងព្រះពុទ្ធប្រាកដមានសភាពដូចព្រះអង្គនេះឯងហោង ។ រីនាងកញ្ញាដ៏ជាប្អូននោះសោត នាងចូលទៅបូជាសុពណ៌មាលាមាស ដ៏ជាគ្រឿងប្រដាប់ព្រះឱរាដល់ព្រះពុទ្ធវិបស្សីស្រេចហើយនៃ នាងធ្វើសច្ចាធិដ្ឋានសូត្រនូវបាទព្រះគាថាដូច្នេះថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

ភន្តេ សុវណ្ណមាលាយ　　មយា តំ បូជិតោ អសិ
តេន មយ្ហំ ឧរេ ហោតុ　　មាលាបូជាយ និម្មិតាតិ ។

ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ហេតុតែតេជៈផលានិសង្សនៃអញខ្ញុំ ថ្វាយបូជាសុពណ៌មាលាមាស ដ៏ជាគ្រឿងប្រដាប់ព្រះឱរាព្រះអង្គនេះ ទោះខ្ញុំម្ចាស់នេះ នឹងអន្ទោលទៅវិញទៅមក យោនយកកំណើតកើតដល់មួយរយជាតិក្តី មួយពាន់ជាតិក្តី វីសុពណ៌មាលាមាសនេះ សូមកុំឲ្យប្រាសអំពីទ្រូងខ្ញុំម្ចាស់ឡើយ ឲ្យមានរៀងរាបដរាបដល់និព្វានហោង ។

វីព្រះពុទ្ធវីបស្សី ព្រះអង្គទ្រង់ព្រះសណ្តាប់ព្រះរាជកញ្ញាទាំងពីរ ប្រាថ្នាដូច្នោះហើយ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ដល់ព្រះរាជកញ្ញាទាំងពីរសូត្រនូវបាទព្រះគាថាដូច្នេះ

យា ចេត្ថ ទ្វីហិ តុម្ហេហិ　　បូជា មយ្ហំ បតិដ្ឋិតា
តាយ ឥច្ឆន្តុ តុម្ហាកំ　　យថា វោ បត្ថនា តថាតិ ។

ថាហែរាជកញ្ញាទាំងពីរអើយ វីក្តីប្រាថ្នាឧបាសិកាទាំងពីរដែលមកបូជាប្រតិស្ឋានដល់អញតថាគតនេះ ចូរឱ្យនាងបានសម្រេច

Websites: WatKhemaraRatanaram.org or WatKhmers.org

បរិបូណ៌ដូចក្ដីបំណងប្រាថ្នាឧបាសិកាហោង ។

រីឯព្រះរាជកញ្ញាទាំងពីរ ស្ដាប់អនុមោទនានៃព្រះតថាគតនូវប្រការអម្បាលណោះហើយ ព្រះនាងទាំងពីរក៏មានព្រះហឫទ័យនោះត្រេកអរ លើកដៃកម្បង់អញ្ជលីដាក់លើសិរសី ថ្វាយបង្គំប្រណម្យក្រាបលា មកកាន់ព្រះរាជមន្ទីរវិញ ។ រីព្រះនាងទាំងពីរ ឋិតនៅនាមនុស្សលោកនេះ ដរាបលុះរំលាងព្រះជន្មាយុអំពីមនុស្ស លោកនេះស្មោះឆ្ពោះបានទៅកើតឰដ៏សួគ៌ទេពលោកនាយ លុះច្យុត អំពីសួគ៌ទេពលោកនាយនោះ មកកើតឰដ៏មនុស្សលោកនេះ លុះរំលាងបញ្ចក្ខន្ធអំពីមនុស្សលោកនេះ ក៏បានទៅកើតឰដ៏សួគ៌ទេពលោកនាយវិញទៀត រៀងរាបដរាប លុះអំណើះអស់កាល ៩១ កប្បហោង ។

រីនាងកញ្ញាដ៏ជាច្បងសោត មកបានជាព្រះកន្លោងព្រះពុទ្ធប្រាកដព្រះនាម ព្រះនាងស្រីមហាមាយាទេវី ។ រីនាងកញ្ញាដ៏ជាប្អូននោះសោត នាងអន្ទោលទៅវិញទៅមក លុះដល់ព្រះពុទ្ធកស្សបៈព្រះអង្គបានត្រាស់ហើយ នាងច្យុតចុះមកចាប់បដិសន្ធិជាព្រះរាជបុត្រីនៃព្រះបាទកឹកិស្សរាជ ហេតុតែតេជៈផលានិសង្សនាងបានយក

Websites: WatKhemaraRatanaram.org or WatKhmers.org

សុពណ៌មាលាមាស ទៅថ្វាយបូជាព្រះពុទ្ធវិបស្សីនោះមិញ នាកាល នាងចាកចេញអំពីព្រះឧទរបវរព្រះមាតានោះ ហាក់បីដូចអ្នកយក សុពណ៌មាលាមាស ជាគ្រឿងប្រដាប់ព្រះឱរា មកប្រដាប់ស្រោបនូវ ព្រះអង្គនាងនោះឯង ហេតុតែនិមិត្តនោះឯង ទើបអស់ព្រះញាតិវង្ស ផងមកសន្មតកត់ព្រះនាមករណ៍ថា ព្រះនាងឧរច្ឆទារាជកុមារី ។ លុះ ព្រះនាងចម្រើនវ័យធំឡើងបានព្រះជន្ម ១៦ វស្សា ព្រះនាងបានស្តាប់ ភត្តានុមោទនា របស់តថាគតជាអម្ចាស់ នាងបានលុះសោតាបត្តិ-ផល ។ ចំណេរអំពីនោះទៅ ព្រះនាងបានស្តាប់ភត្តានុមោទនាមួយ អន្លើនឹងព្រះវររាជបិតា ព្រះនាងបានលុះដល់ប្រាជ្ញាអរហត្ត ហើយព្រះ នាងបួសជាភិក្ខុនីបានចូលនិព្វាន ឮដ៏ជាឋានបរមសុខក្សេមប្រសើរ នោះទៀងប្រាកដហោង ។

សមណី សមណគុត្តា ភិក្ខុនី ភិក្ខុទាសិកា
ធម្មា ចេវ សុធម្មា ច សង្ឃទាសី ច សត្តមាតិ ។

រីព្រះបាទកឹកស្សរាជ ស្តេចមានព្រះរាជបុត្រីដទៃទៀតនោះ ៧ អង្គ ឈ្មោះនាងសមណី ១ ឈ្មោះនាងសមណគុត្តា ១ ឈ្មោះនាង

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុនី ១ ឈ្មោះនាងភិក្ខុទាសិកា ១ ឈ្មោះនាងធម្មា ១ ឈ្មោះនាងសុធម្មា ១ ឈ្មោះនាងសង្ឃទាសី ១ ។ រីព្រះរាជធីតាទាំង ៧ នោះ សឹងបានកើតទាន់ព្រះពុទ្ធុប្បាទ ព្រះសមណគោតមបរមបពិត្រជាអម្ចាស់វិសេសនៃយើងនេះ ។

ខេមា ច ឧប្បលវណ្ណា បដាចារា ច គោតមី
ធម្មទិន្នា មហាមាយា វិសាខា ចាបិ សត្តមាតិ ។

រីព្រះនាងមួយអង្គនោះ បាននាមហៅថា នាងខេមាភិក្ខុនី, នាងមួយបាននាមហៅថានាងឧប្បលវណ្ណាថេរី, នាងមួយបាននាមហៅថានាងបដាចារា, នាងមួយបាននាមហៅថានាងគោតមី, នាងមួយបាននាមហៅថានាងធម្មទិន្នា, នាងមួយបាននាមហៅថានាងមហាមាយា, នាងមួយបាននាមហៅថានាងវិសាខា ។ រីព្រះនាងទាំង ៦ នោះ យើងមិនស្រដីឡើយ យើងនឹងស្រដីតែព្រះនាងសុធម្មាមួយប៉ុណ្ណោះ ព្រះនាងនោះអន្ទោលទៅវិញទៅមក នៅនាឰដ៏សួគ៌ទេពលោកនាយក្តី នៅនាមនុស្សលោកនេះក្តី ហេតុតែផលានិសង្សដែលព្រះនាងបានយកលំអិតខ្លឹមច័ន្ទន៍ ទៅថ្វាយបូជាព្រះពុទ្ធវិបស្សីនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

មិញ កាលណាបើព្រះនាងចាកចេញ អំពីព្រះឧទរព្រះវរមាតា ដ៏មានព្រះអង្គព្រះនាងនោះផុំក្លិនពិដោរ បីដូចអ្នកលាបស្រឡាបនូវលំអិតខ្លឹមច័ន្ទន៍ក្រហម ហេតុតែនិមិត្តដូច្នោះហោង ទើបព្រះនាងបានព្រះនាមថា ព្រះនាងសុបារសុប្បតី ។ ចំណេរអំពីនោះទៅ ព្រះនាងបានជាអគ្គមហេសីនៃព្រះឥន្ទ្រាធិរាជនៅឰដ៏ពិភពត្រៃត្រឹង្ស នាកាលព្រះនាងសោយព្រះវិលាល័យក្ស័យព្រះជន្មាយុ ដោយកំណត់អាយុសួគ៌ទេវលោកនាយនោះកូវ ក៏កើតមានបុព្វនិមិត្ត ៥ ប្រការហោង ។

តេជាហ ភគវា ទិព្វបុប្ផា មិលាយន្តិ សំកិលិស្សន្តិ វត្ថាកច្ឆតោ សេទា មុញ្ចន្តិ កាយោ ទុព្វណ្ណិយោ កីសោ ទេវាសនេជាភិរមន្តិ ទេវានំ ចុតិជម្មតាតិ ។ បពិត្រអើយ ហេតុតែនិមិត្តនោះឯង ទើបព្រះដ៏មានបុណ្យព្រះអង្គមានព្រះបន្ទូល នឹងភិក្ខុផងទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីផ្កាភ្ញីទិព្វនោះស្រស់ល្អ ពុំដែលស្វិតស្រពោនមិញ ក៏ខ្វៃប្រែជាស្វិតស្រពោនវិញ រីសំពត់ទិព្វពុំដែលនឹងជិតក្អែលជាមន្ទិលមិញ ក៏ខ្វៃប្រែជាមានមន្ទិលវិញ រីញើសក្អែលពុំដែលនឹងកើតមានមិញ ក៏ខ្វៃប្រែជាហូរចេញមកអំពី

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្លៀកមានជាមន្ទិលវិញ រីខ្លួនព្រះនាងនោះ ពុំដែលថយកម្លាំងមិញ ក៏ខ្វែប្រែជាស្គាំងស្គមថមថយកម្លាំងវិញ ហើយព្រះនាងនឹងគង់លើគ្រែក្រឡាអាស្នា សម្ដេចពុំស្រណុកឡើយ ភិក្ខុអើយនេះជាសភាពនៃទេវតាទាំងឡាយផង នឹងច្យុតសឹងតែដូច្នោះឯង ។ រីសម្ដេចព្រះឥន្ទ្រាធិរាជ ស្ដេចជ្រាបសភាពជាព្រះនាងសុបារសុប្បតី នឹងអស់ព្រះជន្មាយុអំពីសួគ៌ទេពលោកនោះកូវ ទើបស្ដេចនាំព្រះនាង ទៅកាន់នន្ទវ័នឧទ្យាន ដ៏ជាឋានបំបាត់ទុក្ខសោក មួយអន្លើនូវអស់ស្រីស្រឹង្គារបរិពារផងជាច្រើន ព្រះនាងសុបារសុប្បតីផ្ទំលើគ្រែក្រឡាបន្ទំ បរមសុខសួស្ដីមានព្ធដ៏នន្ទវ័នឧទ្យាន ព្រះឥន្ទ្រាធិរាជឯង ស្ដេចគង់ខាងគ្រែក្រឡាបន្ទំព្រះនាង ហើយស្ដេចមានព្រះបន្ទូលថា ហៃនាងសុបារសុប្បតីទេវីអើយ អញនឹងបង្ហៃរឲ្យពរទាំង ១០ ប្រការឲ្យនាង ចូរនាងទទួលយកពរនេះឯងហោង ។ ព្រះឥន្ទ្រាធិរាជ កាលណាបើនឹងប្រទានពរព្រះនាង ក៏សូត្រនូវបាទព្រះគាថាជាបឋម មាននៅក្នុងព្រះមហាវេស្សន្តរជាតក ដ៏ប្រដាប់នីទៅនូវព្រះ គាថានោះមួយពាន់ដូច្នេះថា ៖

ផុស្សតិ វរវណ្ណាភេ វរស្សុ ឧសជា វរេ

Websites: WatKhemaraRatanaram.org or WatKhmers.org

បបព្យា ចារុបុព្វង្គី          យំ តុយ្ហំ មនសោ បិយន្តិ ។

ផុស្សតិ ថាហៃនាងសុបារសុប្បតី ដ៏ប្រកបនូវបញ្ចពិធកល្យាណី ដ៏មានរស្មីដូចមាស ចូរនាងទទួលយកពរទាំង ១០ ប្រការនេះ ពរឯណាដ៏ជាសម្លាញ់ពេញនូវអំណារ នៃមនុស្សសត្វផងទាំងឡាយ ឮដ៏ផ្ទៃក្រោមទាំងមូល នាមនុស្សលោកនាយ ក៏ចូរនាងទទួលយកពរនោះហោង ។

ព្រះនាងសុបារសុប្បតីទ្រង់ស្តាប់ ពុំជ្រាបសភាពជាព្រះនាងនឹងច្យុតឡើយ ហេតុតែព្រះនាងភ្លេចស្មាតី ទើបព្រះនាងទូលទៅព្រះឥន្ទ្រាធិរាជវិញ សូត្រនូវព្រះគាថាជាគម្រប់ពីរដងថា ៖

ទេវរាជ នមោ ត្យត្ថុ          កឹំ ចាបំ បកតំ មយា
រម្មា ចាវេសិ មំ ឋានា          វាតោវ ធរណីរុហន្តិ ។

ទេវរាជ បពិត្រសម្តេចព្រះឥន្ទ្រាធិរាជប្រសើរអើយ ខ្ញុំអម្ចាស់ សូមថ្វាយបង្គំប្រណម្យព្រះអង្គ តើគឺអញខ្ញុំម្ចាស់ ធ្វើនូវអំពើអ្វីជា ប្រាកដគួរអន់អាក់ថ្នាក់ក្នុងព្រះរាជហឫទ័យនៃព្រះអង្គ ទើបព្រះអង្គមកកម្ចាត់បង់នូវខ្ញុំអម្ចាស់ អំពីឋានសួគ៌ឋានសុខស្រណុកមហិមា

Websites: WatKhemaraRatanaram.org  or  WatKhmers.org

ឧបមាបីដូចជាខ្យល់មាលុតវាត បក់ពន្លកឲ្យភ្លូករលើងឈើផងទាំងឡាយ នៅឰដ៏ផ្ទៃក្រោមមនុស្សលោកនាយ ។ ព្រះឥន្ទ្រាធិរាជ ស្តេចជ្រាបសភាពជាព្រះនាង ភ្លេចស្មារតីដូច្នោះហើយ ទើបព្រះអង្គមានព្រះបន្ទូល សូត្រនូវបាទព្រះគាថាដូច្នោះថា ៖

ន ចេវ តេ កតំ ចាបំ ន ច មេ ត្វមសិ អប្បិយា

បុញ្ញញ្ច តេ បរិក្ខីណំ យេន តេវំ វជាមិហន្តិ ។

ផុស្សតិ ថាហៃនាងសុបារសុប្បតីទេវីអើយ រីអំពើបាបអ្វីនាងនឹងធ្វើឲ្យអន់អាក់ថ្នាក់ចិត្តអញនោះ ឥតអង្គីមានឡើយ នាងអើយហេតុតែអញយល់សភាពក្តីព្រាត់ប្រាស នឹងច្យុតដូច្នោះឯង ហេតុនេះហោង ចូរនាងទទួលយកពរទាំង ១០ ប្រការនេះអំពីអញ អញនឹងបង្វែរឲ្យនាងហោង ។ អណ្តាប់នោះ ព្រះនាងសុបារសុប្បតីទ្រង់ជ្រាបសភាពថា អាត្មាព្រះនាងនឹងច្យុតចុះមក ឰដ៏មនុស្សលោកនេះដូច្នោះហើយ ទើបព្រះនាងទទួលយកពរទាំង ១០ ប្រការ អំពីសម្តេចព្រះឥន្ទ្រាធិរាជ ក្រាបទូលជាបាទព្រះគាថាដូច្នោះថា ៖

វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ

Websites: WatKhemaraRatanaram.org or WatKhmers.org

សិវិរាជស្ស ភទ្ទន្តេ តត្ថ អស្សំ និវេសនេ ។
នីលនេត្តា នីលភមូ នីលខីរ យថា មិគី
ផុស្សតី នាម នាមេន តត្ថ អស្សំ បុរិន្ទទ ។
បុត្តំ លភេថ វរទំ យាចយោគំ អមច្ឆរី
បូជិតំ បដិរាជូភិ កិត្តិមន្តំ យសស្សិនំ ។
ភព្ភំ មេ ធារយន្តិយា មជ្ឈិមង្គំ អនុណ្ណតំ
កុច្ឆិ អនុណ្ណតោ អស្ស ចាបំវ លិខិតំ សមំ ។
ថនា មេ នប្បវត្តេយ្យុំ បលិតា នស្សន្តុ វាសវ
កាយេ រជោ ន លិម្បេថ វជ្ឈញ្ចាបិ បមោចយេ ។
មយូរកោញ្ចាភិរុទេ នារីវរគណាយុតេ
ខុជ្ជចេលាវកាកិណ្ណេ សូទមាគធវណ្ណិតេ
ចិត្រគ្គឡេរុឃុសិតេ សុរាមំសប្បពោធនេ
សិវិរាជស្ស ភទ្ទន្តេ តត្ថស្សំ មហេសី បិយាតិ ។

បពិត្រសម្តេចព្រះឥន្ទ្រាធិរាជ ដ៏មានអំណាចអាចជាឥស្សរ

Websites: WatKhemaraRatanaram.org or WatKhmers.org

កំពូលនៃអស់ទេវតាផងទាំងឡាយអើយ ខ្ញុំអម្ចាស់សូមឲ្យបានជាអយ្យិអគ្គមហេសីនៃព្រះមហាក្សត្រព្រះបាទសិវិរាជ ដែលគង់គ្រងព្រះរាជមន្ទីរ ឰដ៏ក្រុងជេតុត្តរនគរ ព្រះពរមួយនេះជាបឋម ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមឲ្យមានភ្នែកនោះមូលខ្មៅយង់ ឧបមាបីដូចកូនម្រឹគទើបកើតបានតែឆ្នាំមួយ ហើយឲ្យមានភូមោនោះកោងទ្រទេសទ្រទួយ បីដូចចង្កួយកៅទ័ណ្ឌ ពុំនោះសោតបីដូចព្រះពិស្ណុការកាន់ដងជក់ជ្រលក់ខ្មៅមកគូរមកវាសហោង ព្រះពរនេះឯងជាគម្រប់ពីរ ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមឲ្យបានឈ្មោះថាសុបារសុប្បតីដូចដែលប្រក្រតី នៅឰដ៏ត្រៃត្រឹង្សពិភព ព្រះពរនេះឯងជាគម្រប់បី ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមឲ្យមានកូនប្រុសដ៏ប្រកបនូវកិត្តិយសឲ្យឮទូទ័រអស្ចារ្យ ទាំងប្រលុងសកលជម្ពូទ្វីប អាចកាត់អំណោយទាន ជាឋានពំនាក់នៃស្មូមយាចកផងទាំងឡាយ ព្រះពរនេះឯងជាគំរប់ ៤ ។ បពិត្រសម្តេចព្រះឥន្ទ្រាធិរាជអើយ ខ្ញុំអម្ចាស់ សូមកាលណាបើខ្ញុំអម្ចាស់នឹងទ្រង់គភ៌នោះ កុំឲ្យមានផ្ទៃពោះធំប៉ោងប៉ើសច្រលើសលើសនឹងចុងដង្ហើមនោះឡើយ ឲ្យរាបសុភាពល្អ បីដូចអ្នកយកកាំធ្នូច្រកក្នុងបំពង់នោះឯង ព្រះពរនេះឯងជាគម្រប់ ៥ ។ ព្រះពរមួយសោត

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ញុំអម្ចាស់សូមកុំបីមានដោះសណ្ដាយជាសំណើចនៃអ្នកផងទាំងឡាយទ្បើយ សូមឲ្យមានដោះក្បោះក្បុំ សមនឹងឧរាដូចផ្លែទន្លាប់មាសអ្នកយកមកផ្ទាប់ នៅព្វដ៏ទ្រូងរបស់ខ្ញុំអម្ចាស់ ព្រះពរនេះឯងជាគម្រប់ ៦ ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមកុំឲ្យមានសក់ស្កូវ អាស្រូវអាក្រក់ សូមឲ្យមានសក់ខ្មៅយង់រលង់រលើបដូចស្លាបភមរា ព្រះពរនេះឯងជាគម្រប់ ៧ ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមឲ្យមានសម្បុរនោះល្អិតល្អបីដូចពពិលមាស គិតដ៏អ្នកដុសខាត់កុំបីឲ្យមានជិតដល់នូវផង់ធូលីដីខ្យាច់ទ្បើយ ព្រះពរនេះឯងជាគម្រប់ ៨ ។ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមបានដោះស្រាយ សត្វផងទាំងឡាយឲ្យរួចចេញអំពីទុក្ខទោស គឺលោកដាក់ទ្រុងច្រូលច្រវាក់ខ្នោះឃ្នាងគុកតារាង នាំទៅនឹងសម្លាប់នោះក្ដី ខ្ញុំសូមឲ្យបានដោះអ្នកទោសនោះឯង ឲ្យបានរួចចេញអំពីទុក្ខភ័យ ព្រះពរនេះឯងជាគម្រប់ ៩ ។ ព្រះពរមួយសោតទៀត ខ្ញុំអម្ចាស់សូមឲ្យមានសព្វសត្វគឺ ហង្ស ក្រៀល ក្ងាន ក្ងោក សឹងហើរឆ្វាត់ឆ្វៀលបន្លឺនូវស័ព្ទនោះឮល្វេងល្វើយ ពីរោះឮដ៏ព្រះរាជមន្ទីរ ដ៏ពេញមីរដេរដាសណាស់ណាន់តាន់តាប់នីទៅ នូវគមគាក់ទំពួន ទម្លៃ

តឿ ខ្ទៃ ខ្ទីយ ជាស្រីស្រីង្គារផងច្រើន ហើយសូមឲ្យមានអ្នកប្រាជ្ញរាជបណ្ឌិតចេះធម៌អាចប្រស្នា បីដូចអ្នកសុរាទំពាសាច់ កុំបីឲ្យដាច់ អំពីព្រះរាជមន្ទីររបស់ខ្ញុំអម្ចាស់ឡើយ ព្រះពរនេះឯងជាគម្រប់ ១០ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាចថិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូល នឹងអស់ភិក្ខុផងទាំងឡាយ សូត្រនូវបាទព្រះគាថាដូច្នេះថា

ឥជំ វត្វាន មឃវា ទេវរាជា សុជម្បតិ
ផុស្សតិយា វរំ ទត្វា អនុមោទិត្ថ វាសវោតិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីសម្តេចព្រះឥន្ទ្រាធិរាជជាឥសូរកំពូល នៃអស់ទេវតាផងទាំងឡាយ ព្រះអង្គបង្វៃរពរប្រទានព្រះនាងសុបារសុប្បតីទេវី ស្រេចនូវប្រការអម្បាលណោះហើយ មានព្រះរាជហឫទ័យនោះ ដ៏ពេញនូវអំណរអរក្រៃពេកហោង ។

ទសវរគាថាវណ្ណនា និដ្ឋិតា ។ បពិត្រអើយ អាត្មាភាព

Websites: WatKhemaraRatanaram.org or WatKhmers.org

សំដែងថ្លែងព្រះធម៌វិសេសទេសនាមហាវេស្សន្តរជាតក កណ្ឌទសពរ ដ៏ប្រដាប់ប្រដានីទៅនូវគាថា ១៩ នេះមិញ ក៏សូរេចដោយនូវវេលាកាលដ៏សមគួរបរិបូណ៌ម៉្លេះឯងហោង ។៚

(ចប់កណ្ឌទសពរទី ១ តែប៉ុណ្ណោះ)

---

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វធាជំ ជម្មធាជំ ជិជាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org